កែប ប៊ុនធឿន

# ប្រវត្តិ

# ខ្លះលើព្រំដែនខ្មែរខាងកើត ជាតិ ទឹកដី និង ប្រវត្តិសាស្ត្រ

បោះពុម្ពលើកទី១
នៅទីក្រុងម៉ុងរេអាល់
កាណាដា

ខែ តុលា ឆ្នាំ ១៩៩៦

ÉDITIONS APSARA

C. P. 232 Succursale M, Montréal (Québec) H1V 3L8 Canada

Titre:
***CAMBODGE:***
***"Frontière de l'est - Nation, histoire"***
Auteur: ***KEO Buntheoun***
Version: *Khmère*

*ចំណងជើង:*

**ប្រវត្តិព្រំដែនខ្មែរខាងកើត**
**ជាតិ ទឹកដី និង ប្រវត្តិសាស្ត្រ**

*និពន្ធដោយ:* **កែវ ប៊ុនធឿន**

*គ្រឹះស្ថានបោះពុម្ព*

**គេហដ្ឋានផ្សាយអប្សរា**

Publié par
***ÉDITIONS APSARA***
C.P. 232 Succursale M
Montréal, Québec H1V 3L8
Téléphone:(514)596-0896 Fax:(514)597-1176

រូបក្របមុខ: ***ចេតិយវត្តតារិយ ស្រុកស្រីសន្ធរ ស.វ.ទី ១៦-១៧***
Couverture: *Stûpa, Vat Tarey, Srey Santhor, XVIè-XVIIè.*

*តំកល់ទុកក្នុងបណ្ណាល័យជាតិ*
***បណ្ណាល័យជាតិកេបិក, បណ្ណាល័យជាតិកាណាដា***
**ត្រីមាសទី ៤ ឆ្នាំ ១៩៩៦**

*Dépôt légal:*
**Bibliothèque nationale du Québec**
**Bibliothèque nationale du Canada**
*Quatrième trimestre 1996*

---

**ISBN: 2-922202-00-3**

---

**ALL RIGHTS RESERVED** **រក្សាសិទ្ធិគ្រប់យ៉ាង** **TOUS DROITS RÉSERVÉS**

"ហាក់បីដូចជាក្តីស្រមៃនិងក្តីយល់សប្តិ
សភាពទាំងឡាយនៅលើលោក
កើតមកតែអំពីចិត្តនិងគំនិតរបស់មនុស្ស
ដែលត្រូវការពិចារណារំពឹងគិត
និងអត្តនោមតិរបស់ខ្លួន ។"

ដកស្រង់ពីវត្តទី៨នៃសិលាចារឹក
វត្តស្រីសន្ធរ-ខែត្រកំពង់ចាម
សតវត្សរ៍ទី១០

# អារម្ភកថា

សៀវភៅស្ដីអំពីប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាយើង ដែលសរសេរជាភាសាជាតិ នៅមានចំនួនតិចតួចស្តួចស្តើងនៅឡើយ ។ ចំពោះខ្មែររស់នៅបរទេស គេអាចមានជាភាសាបរទេសបាន ប៉ុន្តែចំពោះបងប្អូនរួមជាតិយើងនៅក្នុងប្រទេសភាគច្រើនលើសលប់ មិនអាចមានភាសាបរទេសបានទេ ។

ដោយនឹកទៅដល់កុលបុត្រកុលធីតាខ្មែរក្នុងប្រទេសនេះផង ដោយចង់រក្សានិងការពារភាសាខ្មែរឱ្យបានគង់វង្សអង្វែងទៅទៀតផង មូលហេតុទាំងនេះហើយដែលនាំឱ្យយើងខិតខំបង្ហូរចូលក្នុងប្រវត្តិទឹកដីជាតិយើង ជាភាសាខ្មែរ មួយចំណែកបន្ថែមទៀត ។

ប្រវត្តិស្ដីពីព្រំដែនខ្មែរខាងកើតនេះ ពុំមែនជាប្រវត្តិសាស្ត្រទាំងមូលនៃទឹកដីកម្ពុជាយើងទេ គឺគ្រាន់តែជាបំណែកដ៏តូចមួយនៃប្រវត្តិទឹកដីយើង ក្នុងរយៈកាលមួយ ដែលយើងយល់ឃើញថាមានសារៈសំខាន់ដល់មេរៀនប្រវត្តិសាស្ត្រ សំរាប់យើងជាខ្មែរបច្ចុប្បន្ន ។

អ្វីទៅហៅថាប្រវត្តិសាស្ត្រ? សំនួរនេះនៅតែជាប្រធានមួយដ៏ធំធេង ដែលអ្នកប្រវត្តិសាស្ត្រម្នាក់ៗតែងកំណត់ទៅតាមទស្សនៈ និងនិន្នាការរបស់ខ្លួន ។ តើព្រឹត្តិការណ៍ណាខ្លះដែល

# មាតិកា


អារម្ភកថា ........................................ ៧

១. បញ្ហាព្រំដែនយើង
ជាមួយយួននៅកូសាំងស៊ីន(កម្ពុជាក្រោម) ............ ១១

២. ទស្សនៈអំពីព្រំដែនជាខ្សែបន្ទាត់ និង ផែនទី .......... ១៩

៣. ព្រំដែនព្រិល និង ព្រំដែនប្រើឧបសគ្គធម្មជាតិ ....... ២៣

៤. មេរៀនបាត់ទឹកដីដោយសារការបែកបាក់ ............. ២៩

៥. អំពីប្រពៃណីយោធា ........................................ ៤៤

៦. ទស្សនៈយើង ទស្សនៈគេ លើប្រវត្តិសាស្ត្រយើង

- ប្រវត្តិនៃពាក្យ "យួន" ................................ ៥០
- និក្ខេបបទស្តីថា ខ្មែរចំណុះយួនមុនបារាំងមកដល់ ៥៣
- ប្រវត្តិយួនចំណាងដៃ ................................ ៥៦
- ការផ្លាស់ប្តូរនយោបាយរបស់អាណានិគមចំពោះខ្មែរ ៦១

៧. ជាតិ ដើមកំណើត និង ប្រវត្តិសាស្ត្រ ................. ៦៤

ឯកសារសង្កត់ ........................................ ៨៧

អាចកំណត់ចាត់ទុកជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្របាន? សំនួរទាំងពីរនេះ បញ្ជាក់នូវសារៈសំខាន់នៃតួនាទីរបស់អ្នកប្រវត្តិសាស្ត្រក្នុងសង្គម ។

ជាការធម្មតា អ្នកសរសេរប្រវត្តិសាស្ត្រនិងបរិដ្ឋានសង្គមតែងមានឥទ្ធិពលលើគ្នាទៅវិញទៅមក ក្នុងការបកស្រាយព្រឹត្តិការណ៍និមួយៗ ។ ព្រឹត្តិការណ៍ដូចគ្នា តែការបកស្រាយព្រឹត្តិការណ៍ តែងធ្វើឡើងទៅតាមនិន្នាការរបស់អ្នកសរសេរម្នាក់ៗជានិច្ចជៀសមិនផុត ។

ថ្ងៃនេះយើងខិតខំបញ្ចូលក្នុងសួនប្រវត្តិសាស្ត្រជាតិយើងនូវទស្សនៈខ្លះសង្ខេបពីពាក្យថាជាតិ ព្រំដែន ទឹកដី និងប្រវត្តិសាស្ត្រ ។ មូលដ្ឋានទស្សនៈទាំងនេះ ជាការចាំបាច់មួយ ជួយដល់យើងក្នុងការពិចារណាលើបញ្ហាជាតិរបស់យើង ឱ្យកាន់តែបានជ្រៅថែមទៀត ។

សៀវភៅនេះគ្រាន់តែជាការប្រមូលផ្តុំមតិមួយចំនួនស្តីពីប្រវត្តិទឹកដីយើង លើប្រវត្តិជាតិយើង ដោយខិតខំចងចំណងបច្ចុប្បន្នកាលទៅនឹងអតីតកាលរបស់យើង ។ បើយើងជាកូលបុត្រខ្មែរ ឈប់សាសងជាមួយអតីតកាលយើងហើយ ក៏ហាក់ដូចជាយើងឈប់សាសងជាមួយដូនតាយើង ឈប់សាសងជាមួយបុព្វបុរសយើងដែរ ។ វិញ្ញាណក្ខ័ន្ធដូនតាយើង វិញ្ញាណក្ខ័ន្ធបុព្វបុរសយើង ដែលបានពលីជីវិតទៅដើម្បីជាតិ ទឹកដីពិតជាខកចិត្តអាសារបង់ ព្រោះគំរូតស៊ូទាំងនោះ ហាក់ត្រូវបំ

ភ្លេចចោល គំរូការពារទឹកដីនិងត្រូវរលាយបាត់បង់ ។ បើអស់គំរូការពារទឹកដីហើយ យើងមិនអាចការពារទឹកដីយើងឱ្យមានប្រសិទ្ធភាពទេ ។ ហេតុនេះ បើអ្នកណាឈប់សាសងជាមួយអតីតកាលខ្លួនហើយ អ្នកនោះក្លាយទៅជាមនុស្សឥតអតីតកាល ឥតដូនឥតតា ជាកូនកំព្រារងារឥតវិញ្ញាណ ឥតប្រវត្តិកាល មិនដឹងខ្លួនកើតមកពីណាទេ ។ រីឯវិញ្ញាណជាតិក៏ដូច្នេះដែរ ។ វិញ្ញាណជាតិជាស្ពាន សំរាប់ចម្លងជាតិនិមួយៗ ពីដូនពីតាដល់កូនដល់ចៅ ដើម្បីថែរក្សាទឹកដីឱ្យបានគង់វង្សតទៅ ។

*កែវ ពុធរឿន*

២១ ធ្នូ ១៩៩៥

១

# បញ្ហាព្រំដែនយើងជាមួយយួន
# នៅកម្ពុជាក្រោម

ជនរួមជាតិយើងបានដឹងគ្រប់ៗគ្នា អំពីគំនូសព្រំប្រទល់ យើងជាមួយយួនកូស្សាំងស៊ីនដែលចែងក្នុងនិក្ខេបបទដ៏សំខាន់មួយរបស់លោក *សារិនឆាក* ។ ប៉ុន្តែនៅក្នុងសំណុំឯកសារព្រំដែនដែលនេះ យើងសូមបង្គួរចូលបន្ថែមទៀតនូវអត្ថបទពីរដ៏សំខាន់ ដែលយើងបានដកស្រង់ចេញពីសៀវភៅឈ្មោះ ព្រំប្រទល់វៀតណាម(១) ។ អត្ថបទទីមួយ និពន្ធដោយលោក *ម៉ក់ភៀន* ។ អត្ថបទទីពីរ និពន្ធដោយលោក ភីយែរឡាម៉ង់ (Pierre-Lucien Lamant) អ្នកឯកទេសបារាំងផ្នែកប្រវត្តិ

សាស្ត្រកម្ពុជា ។

អត្ថបទទីមួយនិពន្ធដោយលោក ម៉ក់ភឿន ប្រវត្តិវិទូខ្មែរ មានចំណងជើងថា ***"ក្រុមប្រទេសជិតខាងកម្ពុជាគឺសៀមនិងវៀតណាម ទាស់ទែងតវ៉ាគ្នារឿងដីកម្ពុជាក្នុងដំណាក់កាលដែលព្រះរាជអំណាចខ្មែរចុះខ្សោយ"*** ។ អត្ថបទបានសរសេរថា៖

*"ក្នុងរយៈពេលតវ៉ាគ្នាពីក្នុងក្រោយនេះ ក្រុមប្រទេសទាំងនេះតែងតែកើតជម្លោះ ចូលមកក្នុងដីខ្មែរ ដោយសារការរាតត្បាតរបស់ស្តេចក្រុងហ្វេ ។ ជនជាតិយួនតែងតែធ្វើអន្តោប្រវេសន៍ចូលមកក្នុងស្រុកខ្មែរដោយចូលមកតាំងទីលំនៅលើដីខ្មែរ រួចហើយក៏រឹបយកដីនោះថាជាដីរបស់ខ្លួនទៅ ។ ដីទាំងឡាយនេះរបស់ខ្មែរ ស្តេចក្រុងហ្វេរឹបយកទៅគ្រប់គ្រង ដាក់ជាផែនការរបស់ខ្លួនដោយឯកតោភាគី ។ យួនតែងអនុវត្តនយោបាយមួយហៅថានយោបាយអន្តរាគមន៍ ។ តើនយោបាយអន្តរាគមន៍មានរបៀបបទយ៉ាងណាខ្លះ?*

*ទីមួយ យួនតែងញុះញង់ទាញផលប្រយោជន៍ពីជម្លោះរវាងក្សត្រខ្មែរ ។ អង្គក្សត្រខ្មែរខ្លះចង់បានអំណាច ចង់បានរាជបល្ល័ង្ក តែងទៅសុំជំនួយពីក្រុងហ្វេ ។ លុះបានអំណាចហើយក៏ក្លាយទៅជាអ្នកដែលស្ថិតនៅក្រោមឥទ្ធិពលយួនទាំងស្រុង ។ ម្ល៉េះហើយ យួនចង់សំរេចបែបណាក៏បានដែរលើដីកម្ពុជា ។ យួនធ្វើមាត្រា ព្រោះក្រុមប្រទេសរាយប៉ាយជ្រៅចូលមកក្នុងទឹកដីកម្ពុជា ។*

ក្នុងបឹងសភាព្យនេះ ស្តេចក្រុងហ្វេតែងចាត់ទុកព្រំប្រទល់ខ្មែរយួន គ្រាន់តែជាខ្សែបែងចែករដ្ឋបាលគ្រប់គ្រងប៉ុណ្ណោះ ។ ខ្សែព្រំដែនតែងតែទុកឱ្យចំហជានិច្ច ។ នយោបាយទុកព្រំដែនឱ្យចំហដូច្នេះ អនុញ្ញាតឱ្យអាណានិគមជនយួនចូលមកនៅក្នុងដីខ្មែរក៏ស្រួល តែរុំបបង្កិតបន្តទៀតក៏ស្រួល ។ ស្តេចក្រុងហ្វេមិនដែលខ្វល់ដល់ការពារសង្គមខ្មែរ ដល់បញ្ហាមនុស្សធម៌លើដីខ្មែរទេ ។

ក្នុងការរំកិលទឹកដីនេះយួនធ្វើដូចម្តេច? យួនទុកឱ្យរដ្ឋបាលខ្មែរត្រួតត្រាតំបន់ណាដែលមានប្រជាជនខ្មែរសុទ្ធសាធរស់នៅ។ ប៉ុន្តែ យួនដាក់រដ្ឋបាលយួនឱ្យត្រួតតំបន់ ភូមិ ឃុំ ស្រុកណាដែលឱ្យតែមានភូមិយួនមួយពីរនៅលាយក្នុងតំបន់នោះ ទោះបីជាតំបន់នោះជាតំបន់ដែលមានខ្មែរច្រើនលើសលប់យ៉ាងណាក៏ដោយ ។ ការកាត់ផ្តាច់ទឹកដីទាំងនេះ តែងភ្ជាប់ទៅនឹងនយោបាយកាត់ផ្តាច់ចំណងទាក់ទងរវាងខ្មែរនឹងខ្មែរ ដែលរស់នៅសងខាងព្រំដែនថ្មី ។ ការកាត់ផ្តាច់ទឹកដីយកទៅដាក់ក្រោមអំណាចក្រុងហ្វេនេះហើយ ដែលតែងនាំឱ្យមានការប្រឆាំងមានកុប្បកម្មបះបោរឥតឈប់ពីប្រជាជនខ្មែរជាម្ចាស់ស្រុក ។ ខ្មែរជាម្ចាស់ដីពុំដែលព្រមទទួលការត្រួតត្រារបស់យួន ដែលជាអាណានិគមជនបរទេសលើដីខ្លួននោះទេ ។ រឿងហេតុទាំងអស់នេះបញ្ជាក់ថាក្នុងបឹងសភាព្យនេះ ប្រជាជនខ្មែរតែងបដិសេធ មិនទទួលស្គាល់ព្រំដែនដែលយួនប្រើសិទ្ធិបំបែកខ្មែរពីគ្នានោះទេ ។ ព្រំដែនទាំង

នេះគ្មានឈរលើកិច្ចព្រមព្រៀងណាមួយ ទាំងខាងយួនក៏ដូចជាខាងខ្មែរដែរ ។ ព្រំដែនទាំងនេះគួរកាត់ឡើងតាមតែអំពើចិត្តយួនសំរេចជាឯកតោភាគី ពីទីក្រុងហ្វេ ហើយដាក់តម្រូវដោយបារាំងតែប៉ុណ្ណោះ ។"

នៅក្នុងកំណត់ផ្សេងៗអត្ថបទសរសេរថា៖ "ពេលដែលបារាំងមកដល់ មានការគិតយួនមិនទាន់មានទំហឹងពិតប្រាកដ ជាន់ទឹកដីខ្មែរដែលបារាំងហៅថាកូសាំងស៊ីនខាងលិចនេះឲ្យបានដាច់ស្រាច់នៅឡើយទេ" (២) ។ ប៉ុន្តែការកែទម្រង់បែងចែកកាត់ទឹកដីប៉ែកខាងកើតរបស់ខ្មែរ ដែលបារាំងហៅថាកូសាំងស៊ីនប៉ែកខាងលិចខេត្តព្រៃនគរនេះ គឺជាស្នាដៃមូលដ្ឋានរបស់បារាំង (៣) ។ តមកទៀត នៅឆ្នាំ១៩២០ យួនដែលមកតាំងទីរស់នៅក្នុងតំបន់បាសាក់ក្រោម ក៏នៅមានកំរិតនៅឡើយ ហើយមានចំនួនតិចបំផុតជាងខ្មែរម្ចាស់ស្រុកនៅជុំវិញស្វាយទង (យួនហៅទ្រីតុង) និងផងភ្នំកំពូលព្រៃពីរ (៤) ។ នេះជាការដកស្រង់របស់យើងលើអត្ថបទទីមួយ ។

អត្ថបទទីពីរ "ព្រំដែនខ្មែរ-យួនចាប់ពីដាក់កណ្តាលសតវត្សទី១៩មកទល់ឆ្នាំ១៩៥០ របស់លោក ភីលីពគ្លេស្ទៀងឡាម៉ង់ ។ អត្ថបទសរសេរថា៖

"នៅពេលដែលបារាំងចាប់ផ្ដើមគេះទីតាំងនៅកូសាំងស៊ីនខាងក្រោមឆ្នាំ១៨៥៩ ហើយដែលបារាំងចាប់សង្កេតឃើញសារៈសំខាន់នៃផ្ទៃដីដែលហូរស្រោចដោយទន្លេមេគង្គនេះ តើព្រំ

ទេ ។ យួនចូលចិត្តទុកតំបន់ទាំងនេះជា*តំបន់ត្រួសត្រាយរបស់គេ គឺជាតំបន់ចល័ត* ។ យួនកំណត់អត្ថន័យតំបន់ចល័តនេះច្បាស់ គឺប្រើវិធីពីរផ្លាស់គ្នា ប្រែប្រួលទៅតាមសភាពការណ៍និងកម្លាំងរបស់គេ ។ ពេលណាប្រើនិគមមនុស្សបានរួចហើយ គេប្រើយោធាវិសង្គ្រប់ កាត់យកដីត្រួតត្រាតែម្តង ។ ធ្វើដូច្នេះយួនឈានទៅមុខបន្តិចម្តងៗឆ្លងយកសន្ធរមេគង្គ ឆ្ពោះទៅតំបន់ទំនាបមេគង្គ ។

ដោយសារការសរសៀរជ្រៀតចូលបែបនេះហើយ បានជាឯកសារដែលខ្មែរសរសេរនៅពាក់កណ្តាលសតវត្សរ៍ទី១៩ ទាំងប៉ុន្មាន តែងមាននិន្នាការមួយ គឺមិនចង់បញ្ជាក់អ្វីឱ្យច្បាស់លើគោលគំនូសព្រំដែនទេ ។ ការនេះក៏ព្រោះតែខ្មែរបដិសេធមិនទទួលស្គាល់ការរឹបអូសយកទឹកដីខ្លួនពីសំណាក់យួន ។ *ប្រវត្តិសាស្ត្រដ៏រកាំរកូសក្នុងរយៈ៥០ឆ្នាំ នាដើមសតវត្សរ៍ទី១៩ បានផ្តល់នូវសភាពការណ៍មួយយ៉ាងសែនស្មុគស្មាញបំផុត ។ ខេត្តទាំងឡាយដែលហៅថាដីយួនជះជាន់ត្រួតត្រា សុទ្ធតែជាដីដែលរស់នៅដោយប្រជាជនខ្មែរជាច្រើនលើសលប់ ហើយដែលប្រជាជនខ្មែរទាំងនេះ មិនទទួលស្គាល់ត្រួតលើយួន មិនព្រមបង់ពន្ធឱ្យរាំងក្រុងហ្វេ ។ ហេតុនេះ យួនត្រូវបន្តបង្កាក់តំបន់ខ្លះឱ្យមានអធិរាជពីរប្រទាញប្រទង់គ្នា ប្រទាំងគ្នា ។ ប្រជាជននៅតំបន់ភូមិស្រុកក្បាលដីនេះ ត្រូវបង់ពន្ធដាយមហាក្សត្រខ្មែរផងនិងឱ្យស្តេចយួនក្រុងហ្វេផង ។ ភូមិមួយត្រូវរែកពន្ធពីរ ។*

*ហេតុដូច្នេះហើយបានជាទៅដល់បច្ចុប្បន្ន វិញ្ញូវិញ ក្រុមជួនជាច្រើន នៅឆ្នាំ១៩៥៩ ត្រូវបង់ពន្ធដីធ្លាយព្រះបាទធនរាជ្យ ហើយត្រូវបង់ ពន្ធប្រចាំឆ្នាំនិងពន្ធធ្វើការងារ ឲ្យស្ដេចក្រាញ់ញូនទៅវិញ ។*

ចំណែកបារាំងវិញ ក្នុងរយៈពេលដំបូង គ្រាន់តែប្រហាក់ប្រហែលទេអំពីព្រំដែនរវាងអាណាចក្រទាំងពីរ ។ ប៉ុន្តែបារាំងមានចេតនាចង់ដាក់ *ព្រំដែនជាក់លាក់ច្បាស់* ដោយយក *ព្រំដែនធម្មជាតិ* មកប្រើកន្លែងណាដែលប្រើបាន គឺយកឧបសគ្គធម្មជាតិ ដូចជាភ្នំ ទន្លេ មកធ្វើជាគំនូសព្រំដែន ។

បើយោលទៅតាមវិធីសាស្ត្រ ការដោះស្រាយបញ្ហានេះបានត្រូវជួបឧបសគ្គលំបាកច្រើន ។ *ដូច្នេះហើយបានជាឯកសារ សំខាន់ៗ ស្ដីពីការគូសកាត់ព្រំដែន និងការកែប្រែជាបន្តបន្ទាប់ទៀត ក្នុងសម័យអាណានិគមបារាំង ត្រូវបាត់ ឬ ត្រូវទុកក្នុងបណ្ណឯកសារនៅបណ្ណាល័យឯកសារនាយសមុទ្រ នៅ ក្រុងអិចអង់ប្រូវ៉ង់* (Aix-en-Provence) ។ *នៅឆ្នាំ ១៩៥៥ ឯកសារអាណានិគមទាំងប៉ុន្មានបានត្រូវផ្ទេរពីឥណ្ឌូចិនមកបារាំង តាមការទាមទារនៃការិយាល័យកណ្ដាលផ្នែកឯកសារប្រទេសបារាំង។ តាមហេតុផល គឺច្បាស់ជាធ្វើតាមសេចក្ដីត្រូវការតែយ៉ាងនេះ ដើម្បីទាញយកប្រយោជន៍ក្រោយឯករាជ្យ របស់ប្រទេសទាំងបីនៃសហព័ន្ធឥណ្ឌូចិន ។ ប៉ុន្តែឯកសារទាំងនេះមិនមែនរៀបចំតាមលំដាប់ទៀងទាត់យ៉ាង និងយ៉ាងទៀតផងដែរ ទាំងឆ្ងាយពីនិទិកចិត្តទាំងនេះ ត្រូវបាត់បង់ ធ្វើឲ្យរកដំណោះស្រាយបញ្ហាទាំងឆ្ងាយមិនឃើញ* (៥) ។

នេះជាការដកស្រង់របស់យើងអំពីអត្ថបទទីពីរ ។ អត្ថបទទាំងពីរនេះ ជាពិសេសអត្ថបទរបស់លោក ម៉ក់ភៀន ជាភស្តុតាង បំភ្លឺបន្ថែមនិងសង្កត់លើនិក្ខេបបទរបស់លោក សារិនឆាក ឈ្មោះថា "ព្រំដែនខ្មែរ" ដែលបោះផ្សាយដោយ ដាឡូស ឆ្នាំ ១៩៦៦ ។ យើងអំពាវនាវដល់បងប្អូនរួមជាតិ សូមចូលជួយពិចារណាលើអតីតកាលដ៏សែនថ្លៃស្រស់ ហើយដែលប្រវត្តិដដែលនេះកំពុងតែធ្វើឡើងវិញរាល់ថ្ងៃលើកម្ពុជាយើងតាំងពីឆ្នាំ១៩៧៩ មកទល់ថ្ងៃនេះឥតទាន់មានទីបញ្ចប់ ។



## ២

# ទស្សនៈអំពីព្រំដែន ជាខ្សែបន្ទាត់ និងដែនដី

ទស្សនៈនៃគំនូសព្រំដែនជាខ្សែបន្ទាត់សំរាប់ចែកជាតិពីរពីគ្នា គឺជាអន្តរាគមន៍របស់អឺរ៉ុប ដូចលោកឡាម៉ង់បាននិយាយមែន ។ ទស្សនៈខ្សែបន្ទាត់នេះ បានចេញផ្សព្វផ្សាយលើសកលលោក ក្នុងសម័យអាណានិគម (៦) ។ ព្រំដែនខ្សែបន្ទាត់តែងតែកំណត់ឡើង ទៅតាមតែផលធៀបនៃកម្លាំងជាវត្តមាននៅទីនោះ ។ ព្រំដែនជាខ្សែបន្ទាត់នេះ កើតមានបានលុះត្រាណាតែកម្លាំងជាតិទាំងពីរដែលនៅសងខាង អាចព្រួតពិនិត្យខ្សែបន្ទាត់ទៅវិញទៅមកបានរៀងខ្លួន ។ បើពុំដូច្នេះទេ ប្រ

ទេសខ្សោយនឹងក្លាយទៅជាខេត្តរបស់ប្រទេសខ្លាំង ដែលនៅម្ខាងទៀតនៃខ្សែបន្ទាត់ព្រំដែនតែប៉ុណ្ណោះ ។ ឧទាហរណ៍ច្បាស់ ប្រទេសលាវទៅជាខេត្តប្រទេសយួនបច្ចុប្បន្ន ហើយប្រទេសខ្មែរដែលយួនកំពុងធ្វើរាល់ថ្ងៃ ដោយទុកព្រំដែនឱ្យចំហគ្មានខ្សែបន្ទាត់ លប់ខ្សែបន្ទាត់ស្រេចតែលើកម្លាំងយួន ។ បើថ្ងៃនេះ ខ្មែរគ្មានការតស៊ូទេ ខ្សែបន្ទាត់ព្រំដែនខ្មែរ-យួន ដែលសល់ពីសម័យអាណានិគម រហូតមកទល់ឆ្នាំ ១៩៧៩ នឹងក្លាយទៅជាខេត្តរបស់ប្រទេសយួន ដូចជាប្រទេសលាវ ដោយចៀសមិនផុតឡើយ ។

នៅអឺរ៉ុបបច្ចុប្បន្ន ប្រទេសសហគមន៍អឺរ៉ុបទាំងអស់ អនុញ្ញាតឱ្យមនុស្សធ្វើចរាចរ ចេញចូលទៅមកបានមែន ប៉ុន្តែខ្សែបន្ទាត់ព្រំដែនឥតមានលប់ទេ ។ ខ្សែបន្ទាត់ចែកទឹកដីនៅតែជាខ្សែព្រំដែនជានិច្ច ព្រោះនៅសងខាងនៃខ្សែបន្ទាត់នេះ ជាតិនិមួយៗប្រើកម្លាំងច្បាប់របស់ខ្លួន គឺប៉ូលីស-យោធា-គយ ត្រួតត្រាទឹកដីរបស់គេ ។ អ្នកណាធ្វើការ រស់នៅ ខាងណា ត្រូវបង់ពន្ធគោរពច្បាប់ខាងនោះ ។

នៅក្នុងបញ្ហាគំនូសព្រំដែន មានបញ្ហាគំនូសទាញខ្សែដាក់បង្គោលនៅលើដី ប៉ុន្តែពាក្យថា គំនូស គឺមានអ្នកគូរផែនទី ។ ផែនទីព្រំដែន តែងតែកាន់កាប់ដោយក្រសួងការពារប្រទេសមុនគេ ។ ការងារគូសផែនទី ត្រឹមណា ដល់ណា គឺជាការសំរេចរបស់កម្លាំងយោធា ។ បើមើលផែនទីទាំងឡាយរបស់

ប្រទេសកម្ពុជាវិញ យើងឃើញថា ផែនទីទាំងឡាយដែលគូស ដាក់ខ្សែព្រំដែនចន្លោះស្រុកខ្មែរ និង យួន មុនបារាំងមកដល់ គឺសុទ្ធតែជាខ្សែបន្ទាត់ប្រឌិត គូរឡើងតាមតែចិត្តអ្នកគូរផែនទី តែប៉ុណ្ណោះ ។

ចំពោះតំបន់ដែលយួនចូលមកបោះទីតាំងទាំងឡាយនៅ កម្ពុជាក្រោម យើងអាចផ្អែកលើឯកសាររបស់លោក ម៉ាក់ភៀន បាន ដែលយើងសូមជូនផែនទីនៅខាងក្រោយ ។

នៅក្នុងសម័យអាណានិគម បុគ្គលិកទាំងអស់នៃក្រសួង ឯកសារ ក្រៅពីបារាំង មានតែយួនទេ ។ នៅក្នុងក្រសួងភូមិ សាស្ត្រផែនទីសុរិយោដី នៅហាណូយក្តី នៅភ្នំពេញក្តី គឺសុទ្ធ តែយួន ១០០% ។ គ្មានខ្មែរម្នាក់ទេ នៅសុរិយោដីក្នុងសម័យ អាណានិគម។ លោកហ្សង់ដែលវែរ (Jean Delvert) ធ្លាប់ បានត្អូញត្អែរជាច្រើនផង អំពីបញ្ហានេះ ក្នុងសៀវភៅរបស់គាត់ ឈ្មោះ "កសិករខ្មែរ" (៧) ។ ហេតុនេះ គ្មានអ្វីគួរឱ្យឆ្ងល់ទេ អំពីការបាត់បង់ឯកសារនិងផែនទីសំខាន់ៗ នៅពេលដែលគេ ផ្ទេរឯកសារផែនទីទាំងឡាយ ចេញពីភ្នំពេញ ពីព្រៃនគរ និង ពីហាណូយ យកទៅទីក្រុងប៉ារីស ។ នៅពេលនោះ ផែនទី កម្ពុជា សុទ្ធតែយកទៅបោះពុម្ពនៅព្រៃនគរ ពុំមែនឱ្យបោះពុម្ព នៅភ្នំពេញទេ ។ ទោះបីជានៅថ្ងៃនេះហើយក្តី ឆ្នាំ ១៩៩៥ ហើយក្តី ក៏នៅក្នុងក្រសួងរដ្ឋ ផ្នែកសុរិយោដីនៅភ្នំពេញ មាន សុទ្ធតែយួនជាអ្នកត្រួតត្រា ។ យើងធ្លាប់នឹងស្រាប់ហើយថា

បុគ្គលិកស៊ីវិលយោធាយួន តែងតែផ្លៀតប្ដូរឈ្មោះភូមិខ្មែរ ឃុំ ស្រុក ខេត្តរបស់ខ្មែរ ទៅជាឈ្មោះយួន លើផែនទី និងឯកសារទាំងឡាយ ។ លោក ហ៊ឺ ធីម បានជូនភស្តុតាងយ៉ាងច្រើន ក្នុងវិញ្ញាសាររបស់លោក (៨) ។



## ៣

# ព្រំដែនព្រិល
# និងព្រំដែនប្រើឧបស័គ្គឆម្ពូជាតិ

ប្រទេសយួនតាំងពីនៅមានឈ្មោះជាអាណ្ណាមក៏ដោយ ក៏មិនដែលចង់ឱ្យមានព្រំដែនមួយច្បាស់លាស់ជាមួយខ្មែរទេ ។ យួនចង់ឱ្យមានតែកំណត់មួយយ៉ាងព្រិលបំផុត ។ យួនធ្វើយ៉ាងណាកុំឱ្យកំណត់ព្រិលនេះ ក្លាយទៅជាឧបស័គ្គដល់និគមយួន ដើម្បីចូលមករស់នៅក្នុងទឹកដីខ្មែរ ។ បើយើងពិនិត្យមើលបញ្ហាព្រំដែន តើមកទល់ថ្ងៃនេះ ឆ្នាំ១៩៩៥ សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលឈប់អនុវត្តនយោបាយខាងលើនេះម្ដងណាដែរឬទេ? តើយើងចាំបាច់ធ្វើដូចម្ដេចទៅដើម្បី

ទប់ទល់ការឈ្លានពានជាអចិន្ត្រៃយ៍ ដែលគ្មានប្រទេសឯករាជ្យណាមួយក្នុងលោក អាចទ្រាំទ្របាននោះ? យើងចាំបាច់រួមគ្នាធ្វើការពិចារណា ។ ផលវិបាកនៃព្រំដែនព្រិលនៅកម្ពុជាក្រោមបានធ្វើឱ្យការរួមរស់រវាងខ្មែរនិងយួននេះ ក្លាយទៅជាការមួយលំបាក ជាទុក្ខវេទនាមួយដែលបងប្អូនខ្មែរយើងពិបាកលេបជាទីបំផុត។ ឧទាហរណ៍ដ៏តូចមួយ គឺពីមុនយួនតែងយកទឹកកំបោរសទៅលាបលប់លើគំនូរជញ្ជាំងព្រះវិហារខ្មែរ។ លុះក្រោយមកយួនយកបិលដូស្នែរទៅឈូសកំទេចព្រះវិហារខ្មែរតែម្តង។ យួនបិទសាលារៀនភាសាខ្មែរ ។ ដើម្បីរៀន បងប្អូនខ្មែរយើងនៅកម្ពុជាក្រោមវេទនាណាស់ ត្រូវលួចបង្រៀនដោយដាក់ឃ្លាំយាម ។ ហេតុការណ៍នេះមានជាប្រចាំមកដល់បច្ចុប្បន្ន ព្រោះយួនមានវិធានការកំទេចសាសនា វប្បធម៌ខ្មែរ ឱ្យរលប់អស់ពីកម្ពុជាក្រោម ។

គួរឱ្យអនិច្ចាលើបញ្ហាព្រំដែន គំនូសព្រំប្រទល់ទាំងប៉ុន្មានដែលបារាំងបានគូសកំណត់រវាងកម្ពុជានិងកូសាំងស៊ីន មានភាគតិចតួចស្ទួចស្តើងណាស់ ដែលយកឧបសគ្គធម្មជាតិមកប្រើជាខ្សែបន្ទាត់បែងចែកទឹកដី ។ ឧទាហរណ៍ តំបន់នៅខាងត្បូង ***ព្រែកជីក*** (យួនហៅវិញតេ) មានប្រជាជនលើសលប់ ជាខ្មែររស់នៅខាងត្បូងព្រែក ។ ប៉ុន្តែគេកាត់តំបន់ខាងត្បូង គេកាត់ព្រែកជីក គេកាត់ដីចូលជំរៅបីគីឡូម៉ែត្រខាងកើតព្រែកជីកនេះឱ្យទៅយួន ។ តំបន់កម្ពុជាក្រោមទាំងនេះ ជាតំបន់របស់ដីខ្មែរ

។ សម័យអង្គឌួង ស្តេចបានចាត់មេទ័ព *កែប* ធ្វើជាអ្នកត្រួតទឹកដីខ្មែរតំបន់នេះ ហៅថាតំបន់ពាម (យួនដាក់ថាហាទៀង) ។ ឯកសារលោក *ម៉ាក់ហ្គៀរ* សរសេរថា៖ នៅឆ្នាំ១៨៥៨ ពេលដែលបារាំងរវល់ជាប់ប្រតិបត្តិការនៅស្រុកយួន ចៅហ្វាយខេត្តតំបន់ពាម លោកឧកញ៉ារាជសិទ្ធិកែប បានទទួលបញ្ជាពី *ព្រះហរិរក្សរាមាអង្គឌួង* ឱ្យលើកទ័ពទៅយកខេត្តទាំងត្រើយត្បូង (យួនដាក់ថាទ្រិញបឹញ) និងដណ្តើមយកខេត្តបាសាក់ ព្រះត្រពាំង ក្រមួនស និងមាត់ជ្រូកមកកាន់កាប់វិញ ។

ក្រោយពេលដែលព្រះបាទ *នរោត្តម* ឡើងសោយរាជ្យហើយក៏ដោយ នៅឆ្នាំ១៨៦០ ឯកសារអឺរ៉ុបស្តីពីនរោត្តមនិងព្រះរាជពង្សាវតារខ្មែរ បានសរសេរថា៖ "*ព្រះមហាក្សត្របានតែងតាំងចៅហ្វាយខេត្តពាម ឧកញ៉ារាជសិទ្ធិកែប ជាមន្ត្រីខាងយោធា និងប្រគល់ឱ្យកាន់ការជាមួយបញ្ហាការប្រតិបត្តិការលើតំបន់ខាងត្បូងព្រែកជីក តំបន់កំពង់ក្រាស*" (ឥឡូវយួនហៅទិញបៀន) ។ នៅឆ្នាំ ១៨៦៩ អ្នកស្រាវជ្រាវភូគព្ភសាស្ត្រម្នាក់ឈ្មោះ ប៉េទីតុង(Pétiton) (៩) បានសរសេរអំពីខ្មែរនៅទិញបៀនថា *គាត់ត្រូវការអ្នកនាំផ្លូវចេះភាសាខ្មែរ ដើម្បីចូលទៅធ្វើការនៅតំបន់នេះ។* អំពីតំបន់ដែលត្រួតត្រាដោយឧកញ៉ាមហាមន្ត្រីកែបដដែលនេះ ឯកសាររបស់លោក ឌូដាដឺឡាគ្រេ (Doudard De Lagrée) សរសេរថា៖

"*ក្រោយពីទំនាស់ខ្មែរ-យួនលើបញ្ហាខាយ-ថ្លា លោកមហា*

*មន្ត្រីកែប បានលើកទ័ពដេញយួន-ចាម-ជ្វា រហូតទៅដល់ទ្រាំងត្រើយត្បូង ហើយកាន់កាប់ត្រួតត្រាតំបន់នេះឡើងវិញ ។ យួន-ចាម-ជ្វាត្រូវនាំស្លួយសារមាការមកថ្វាយព្រះចៅក្រុងឧត្តុង្គ ដោយឥតមានការជំទាស់ពីយួនរហូត ដល់អាណានិគមចូលដល់កម្ពុជា* (១០) ។ ប្រតិបត្តិការរបស់មន្ត្រីកែបច្បាស់ជាមានការទាក់ទងជាមួយការបះបោររបស់ខ្មែរ ដែលដឹកនាំដោយចៅហ្វាយខេត្តរងនៃតំបន់បាសាក់ឈ្មោះ *ស៊ើម* ។ អនុចៅហ្វាយខេត្ត *ឈឹម* បានប៉ុនប៉ងរំលាស់នឹមយួនតាំងពីឆ្នាំ១៨៥៥ ហើយធ្វើឱ្យយួនបាក់ទ័ពរត់នៅឆ្នាំ១៨៦០។ ការបះបោររបស់ខ្មែរផ្ដួលរំលំយួននេះ ចេះតែលេចឡើងបន្តគ្នាឥតឈប់ រហូតដល់ពេលដែលបារាំងចូលមកកាន់កាប់តំបន់ទាំងនេះ ។ ដំបូងឡើយបារាំងបានសហការជាមួយខ្មែរ ហើយនៅជំនាន់នោះ បារាំងបានដាក់មេស្រុក-មេភូមិជារាជការខ្មែរ ។ ខ្មែរបានត្រឡប់ទៅជាម្ចាស់ផែនដីខាងត្បូងព្រែកជីករបស់ខ្លួនវិញ ជាពិសេសខេត្តទ្រាំងត្រើយត្បូង ដែលមានទំហំទាល់ពីព្រែកជីក កាត់តាមស្វាយទង លាតសន្ធឹងទៅដល់ភ្នំធំ (យួនហៅណូយសាប) ដែលមានព្រែកក្រមួនស ហូរកាត់ជើងភ្នំ (១១)_(១២) ។

តាមឯកសាររបស់លោក *សារិនដាក* ព្រំដែនដែលគុះកាត់ដោយអាជ្ញាធរបារាំង ក្នុងតំបន់ព្រែកជីកនេះ ខ្សែបន្ទាត់ទ័ណ្ឌឥតស្ថិតនៅកណ្ដាលព្រែកជីក ដូចដែលយើងរង់ចាំចង់បាននោះទេ ។ ខ្សែបន្ទាត់ទ័ណ្ឌព្រំដែនខ្មែរ-យួននេះ ស្ថិតនៅបី

គីឡូម៉ែត្រខាងជើងព្រែកជីកទៅទៀត ។ បើនិយាយតាមយុទ្ធសាស្ត្រយោធា វាជាការច្បាស់ក្រឡែតណាស់ ថាអាណានិគមបារាំងឱ្យប្រៀបជាយុទ្ធសាស្ត្រទៅយួន ។ យើងមិននិយាយឡើយ អំពីការបង្អត់ទឹកប្រជាជនខ្មែរ ដែលលែងមានសិទ្ធិទៅផងទឹកក្នុងព្រែកជីករបស់ខ្លួន ។ គ្មានអ្វីដែលអយុត្តិធម៌ជាងនេះទៀតទេ ប្រការបែបនេះចេះតែកើតឡើងនៅស្ទើរគ្រប់ព្រែក គ្រប់ស្ទឹងផ្សេងៗទៀត ដូចជាស្ទឹងនៅចូដុក ជាដើមក៏ដូច្នេះដែរ ។ យើងមិននិយាយផង អំពីខ្ពង់រាបដាឡាត់ ឡុកនិញ ។ល។និង។ល។ ដែលអាណានិគមកាត់ទាំងទទឹងទិសឱ្យចំណេញទៅយួន ។ បើយើងឈរសម្លឹងមើលទៅកោះត្រល់ដែលនៅចម្ងាយតែបួនគីឡូម៉ែត្រពីមាត់សមុទ្រខ្មែរ ហើយដែលស្ថិតនៅចម្ងាយដល់ទៅ ២០ គីឡូម៉ែត្រពីកូស្សាំងស៊ីន ត្រូវបានបារាំងកាត់ប្រគល់ទៅឱ្យយួននៅឆ្នាំណា? គឺម្សិលមិញសោះ ឆ្នាំ ១៩៣៩(១៣) ។ ពីម្សិលមិញទៀត គឺនៅឆ្នាំ១៩៤៩ នៅពេលដែលបារាំងបំរុងប្រគល់ទឹកដីកម្ពុជាក្រោម ដែលបារាំងគេហៅថាកូស្សាំងស៊ីនបារាំងទាំងមូលឱ្យទៅបាវដាយ ព្រឹទ្ធសភាបារាំងភាគច្រើនចង់សំរបសំរួលតាមប្រតិភូខ្មែរ ដែលទាមទារឱ្យពិនិត្យឡើងវិញ នូវសំណុំរឿងព្រំដែនប្រទេសទាំងពីរ ។ ឧត្តមសេនីយ៍ ***ឌឺហ្គោល*** បានប្រកាន់យកជំហរការពារគោលការណ៍នេះ(១៤) ។ ចុះហេតុអ្វីក៏យើងមិនឆក់យកឱកាសនេះការពារទឹកដីយើងឱ្យបាន? តើជាការខ្វះខាតរបស់អ្នកណា? តើ

កាសែត ខេមរជាតិ
Khemarajati

*សហព័ន្ធសារព័ត៌មានខ្មែរនៅបរទេស*

អាន **ខេមរជាតិ...** គឺក្រុបជញ្ជាក់

**ខ្លឹមសារនៃគោលជំហរជាតិនិយមខ្មែរ**

សូមសរសេរទាក់ទងមក៖

C.P. 232 SUCCURSALE M
MONTRÉAL QUÉBEC H1V 3L8 CANADA
TÉLÉPHONE.(514)596-0896 FAX.(514)596-1176

## ៨

# មេរៀនបាត់ទឹកដី ដោយសារការបែកបាក់

ក្នុងមេរៀនប្រវត្តិសាស្ត្រ យើងបានឃើញជានិច្ចជាកាល ថាពេលណាក៏យួនឆ្លៀតប្រើការបែកបាក់ផ្ទៃក្នុងខ្មែរ ឆ្លៀតប្រើភាពល្ងង់ខ្លៅរបស់យើង ដើម្បីអនុវត្តនយោបាយកកេរទឹកដីយើងជានិច្ច ។ ខ្មែរទាំងអស់ដឹងគ្រប់ៗគ្នា ។ ក្នុងបញ្ហានេះ យើងចាំបាច់ចាប់អារម្មណ៍ ដាស់សតិសម្បជញ្ញៈយើង លើកកត្តាពីរដ៏សំខាន់ ដែលបេះពីគ្នាមិនដាច់ ***គឺភាពល្ងង់ខ្លៅជាឫសគល់នៃការបែកបាក់ផ្ទៃក្នុង*** ។ ក្នុងបញ្ហានីមួយៗ ការវិនិច្ឆ័យជាការងាយស្រួលនិងឆាប់រហ័សជាងការវិភាគរកយល់បញ្ហានោះ ។

មេរៀនសកលបានបង្ហាញយ៉ាងច្បាស់ថា ប្រជាជនណាមានការចេះដឹងច្រើន ប្រជាជននោះមិនអាចត្រូវគេជិះជាន់បានយូរទេ ។ ឧទាហរណ៍ ប្រជាជនអាល្លឺម៉ង់ និង ជប៉ុន ។ ហេតុនេះ តើពុំមែនជាការបន្ទាន់ទេឬនឹងចាប់ផ្ដើមធ្វើការអភិវឌ្ឍន៍ខាងផ្នែកអប់រំដល់ប្រជាជនយើង ឱ្យមានការចេះដឹងខ្ពស់ទៅតាមការមានលើគ្រប់បញ្ហាទំនើប សម័យ ឬ បុរាណ ដោយប្រើភាសាជាតិ គឺភាសាខ្មែរសាមញ្ញ? ការអភិវឌ្ឍន៍ខាងការចេះដឹងខ្ពស់អាចប្រព្រឹត្តទៅបាន លុះត្រាណាតែមានកិច្ចសហការយ៉ាងជិតស្និទ្ធ ៖

- រវាងបញ្ញាវ័ន្តស្នេហាជាតិខ្មែរទាំងអស់ គ្រប់ប្រភេទ គ្រប់កំរិត ទាំងទំនើប ទាំងបូរាណ ទាំងឧត្ដមសិក្សា ទាំងសាលាបាលី ។
- រវាងបញ្ញាវ័ន្ត និង ប្រជាជន ។
- រវាងខ្មែរនៅបរទេស និង ខ្មែរនៅក្នុងប្រទេស ។

ការប្រយុទ្ធនេះមានឯកភាពបាន លុះត្រាណាតែមានកិច្ចសហការពីកំពូលទៅដល់បាតក្រោម និងពីជើងមេឃម្ខាងទៅជើងមេឃម្ខាងទៀតនៃសង្គមជាតិយើង ។ ការផ្សព្វផ្សាយវិជ្ជាខ្ពស់ ពុំមែនស្ថិតនៅតែក្នុងសាលារៀនទេ គេរៀនបានគ្រប់ទីកន្លែង ដរាបណាគេមានសៀវភៅសំរាប់អាន សំរាប់ត្រិះរិះពិចារណាបាន ។ ហេតុនេះ សៀវភៅនិងការសរសេរជាការចាំបាច់ ។ ការសរសេរជាភាសាជាតិ ដែលប្រជារាស្ត្រអាច

មានយល់ ណោងចាប់បានជាការចាំបាច់មួយទៀត ។ ដើម្បីមានសៀវភៅ ត្រូវមានអ្នកសរសេរ ។ មានអ្នកសរសេរនិពន្ធហើយ ត្រូវមានរោងពុម្ពបោះផ្សាយសំណេរ ។ ហេតុនេះហើយ បានជាយើងចង់សង្កត់អំពីសារៈសំខាន់នៃរោងពុម្ព និងប្រវត្តិរោងពុម្ពនៅលើផែនដីមនុស្ស ។

នៅសតវត្សរ៍ទី ២ មុនគ.ស. ប្រទេសចិនជាអ្នកចេះបង្កើតក្រដាសមុនគេ ហើយជាអ្នកបង្កើតការបោះពុម្ពអក្សរមុនគេនៅដើមគ.ស. ។ គេដឹងថា នៅសតវត្សរ៍ទី៨ ការបោះពុម្ពលើក្រដាស ប្រើសំរាប់តែបោះអត្ថបទផ្លូវការ ឬអត្ថបទសំខាន់ៗរបស់សាសនាតែប៉ុណ្ណោះ ។ បណ្ណាល័យមានតែជារបស់រដ្ឋរបស់ស្តេចផែនដី ឬរបស់ស្តេចសាសនាផ្សេងៗតែប៉ុណ្ណោះ ។ ប្រជារាស្ត្រសាមញ្ញគ្មានបណ្ណាល័យទេ ។ មុនសតវត្សរ៍ទី១១ នៅអឺរ៉ុប គេសរសេរតែលើស្លឹកផ្កាពីរុស ឬលើស្បែក គេឥតស្គាល់ក្រដាសទេ ។ ទាល់តែដល់សតវត្សរ៍ទី១១ក្រោយគ.ស. ទើបពួកអេស្ប៉ាញ៉ុលចាប់បញ្ចូលក្រដាសមកអឺរ៉ុប ។ អឺរ៉ុបចាប់មានបណ្ណាល័យឯកជន ។ ការប្រជែងប្រណាំងគ្នារវាងក្រុមផ្សេងៗ និងសកលវិទ្យាល័យផ្សេងៗ នាំឱ្យបណ្ណាល័យឯកជន ឬសាធារណៈ ដុះរាលដាលឡើង និងនាំឱ្យគេចាំបាច់រៀបចំឡើងវិញនូវរបៀបបោះពុម្ពទំនើប គឺរោងពុម្ពដែលដុះឡើងតាមមាត់ទន្លេរ៉ាំង (Le Rhin) បង្កើតដោយហ្គូតតង់ប៊ែរ (Gutenberg) នៅឆ្នាំ១៤៤៨ ។ រោងពុម្ពថ្មីរបស់ហ្គូតតង់ប៊ែរនៅ

មាត់ទន្លេរាំងប្រទេសអាល្លឺម៉ាញនេះ ជាការរីកចំរើនអស្ចារ្យណាស់ខាងការផ្សាយចំណេះទូទៅនៅអឺរ៉ុប ។ គឺជាក្បាលម៉ាស៊ីននៃការផ្សព្វផ្សាយចំណេះនៅអឺរ៉ុប និង ធ្វើឱ្យភាសាជាតិរបស់គេរីកចំរើនឥតឈប់ ។

អំពីប្រពៃណីដាក់បណ្ណាល័យតាមវិជ្ជាស្ថាន និងតាមផ្ទះឯកជន ពួកក្រិចបានផ្តើមមុនគេតាំងពីសតវត្សរ៍ទី៥មុនគ.ស. ដូចជាអារីស្តូត ដែលមានបណ្ណាល័យឯកជនរបស់ខ្លួន ។ សម័យពូឡេមេនៅប្រទេសអេហ្ស៊ីប បណ្ណាល័យដ៏ល្បីជាងគេ នៅអាឡិចហ្សង់ទ្រី ៣សតវត្សរ៍មុនគ.ស. ។ ការកសាងបណ្ណាល័យនេះហើយដែលនាំឱ្យអារ្យធម៌នៅអាឡិចហ្សង់ទ្រី (Alexandrie) ប្រទេសអេហ្ស៊ីប ក្រោមរាជពូឡេមេនេះ មានពន្លឺចាំងចែងខ្លាំងណាស់ ក្នុងសតវត្សរ៍ទី៣មុនគ.ស. ។ នៅប្រទេសខ្មែរយើង ការសរសេរលើស្លឹករឹត ច្បាស់ជាមានចំណាស់ចាស់យូរមុនសម័យអង្គរដែលសរសេរលើថ្ម ។ ជាបន្តមក យើងឃើញថា នៅក្នុងព្រះប្រាសាទអង្គរ មានរោងវែង ជាមន្ទីរតម្កល់គម្ពីរ គឺបណ្ណាល័យ ។ ជាប្រពៃណី ខ្មែរតែងរក្សាគម្ពីរក្នុងវាំងស្តេចនិងក្នុងទីវត្តអារាមរបស់ព្រះពុទ្ធសាសនា ។ ហេតុនេះ ខ្មែរតែងសរសេរលើស្លឹករឹត រហូតដល់សតវត្សរ៍ទី២០ ទើបសរសេរលើក្រដាស ។

នៅអឺរ៉ុបនាសតវត្សរ៍ទី ១៥ សេចក្តីត្រូវការសៀវភៅផុលផុសខ្លាំងពេក នាំឱ្យរោងពុម្ពចេះតែផុះគ្រប់ទីកន្លែង ក្នុងរយៈពេ

៥០ឆ្នាំ ។ ព្រឹត្តិការណ៍នេះហើយ ដែលនាំឱ្យមានការរីកចំរើនខាងការផ្សព្វផ្សាយយ៉ាងឆាប់រហ័សអំពីចំណេះវិជ្ជា និងទស្សនៈផ្សេងៗនៅអឺរ៉ុប ។ គឺកំណើតរោងពុម្ពនេះហើយដែលជាមូលដ្ឋាននៃបរមានុភាព (Suprématie) របស់អឺរ៉ុបនៅលើសកលលោកសព្វថ្ងៃ ។

ចំណេះវិជ្ជា ដែលផ្សព្វផ្សាយដោយរោងពុម្ពនេះហើយ ដែលជាកត្តានាំឱ្យមានការរីកចំរើនយ៉ាងខ្លាំងនៅអឺរ៉ុប ជំនាន់រ៉ឺណេសង់ (Renaissance) នាំឱ្យអឺរ៉ុបចេញស្វែងទន្ទ្រានយកដីនៅអាមេរិក ។ល។និង។ល។ នាំឱ្យអឺរ៉ុបពង្រីកវិទ្យាសាស្ត្រ ពីជំនាន់កូពែរនីក ហ្គាលីឡេ ញូវតុន ។ល។និង។ល។

សូមកត់សំគាល់ថា ប្រទេសអារ៉ាប់ចាប់យល់ពីសារៈសំខាន់នៃរោងពុម្ព នៅដើមសតវត្សរ៍ទី១តែប៉ុណ្ណោះ ។ រោងពុម្ពទី១ ចូលមកប្រទេសអារ៉ាប់ គឺនៅអេហ្ស៊ីប ឆ្នាំ១៧០៦ ។ ពីអឺរ៉ុបមកអារ៉ាប់ រោងពុម្ពត្រូវប្រើពេលពីរសតវត្សរ៍កន្លះ ទើបធ្វើដំណើរដល់ដីអារ៉ាប់ ។ នៅអាស៊ីអគ្នេយ៍ រោងពុម្ពទី១ បានតម្លើងនៅបាងកកវាងឆ្នាំ១៨៤០ ដោយស្តេចសៀមឈ្មោះព្រះបាទមង្កុត នៅក្នុងវត្ត សំរាប់បោះពុម្ពធម៌ព្រះពុទ្ធតាមផ្លូវធម្មយុត្តិ ។

នៅកម្ពុជាយើង គម្ពីរទាំងឡាយសរសេរលើសាស្ត្រាស្លឹករឹត ។ បណ្ណាល័យនៅប្រាសាទអង្គរវត្តបញ្ជាក់ថា ខ្មែរមានបណ្ណាល័យរក្សាគម្ពីរសាសនា នាជំនាន់អង្គរ ។ រីឯរោងពុម្ពបោះអក្សរខ្មែរលើក្រដាសទី១ មុនគេ គឺជំនាន់អាណានិគម ក្នុងឆ្នាំ

១៩០៨ នៅភ្នំពេញ(១៦) ។ រោងពុម្ពនេះស្ថិតនៅក្រោមអាជ្ញាធរអាណានិគមបារាំងកាន់កាប់ ពុំមែនជាឯកជនទេ ។ ការបោះពុម្ពផ្សាយត្រូវសុំច្បាប់ពីគណៈរដ្ឋមន្ត្រី និងពីគណៈកម្មការមហានិកាយទាំងពីរ ។ សូមរំលឹកថា គណៈរដ្ឋមន្ត្រីស្ថិតនៅក្រោមការដឹកនាំរបស់រេស៊ីដង់ស៊ុពេរីយ៉េរបារាំង ។ កាសែតខ្មែរទី១ ជាភាសាជាតិខ្មែរគឺកាសែត *នគរវត្ត* បោះពុម្ពនៅឆ្នាំ១៩៣៦ ។ សៀវភៅឈ្មោះ *ការសាកល្បងលើភាសាខ្មែរ* របស់លោក *សៀវហ៊ីម* ត្រូវបោះពុម្ពផ្សាយក្រោយមរណភាពរបស់លោក នៅឆ្នាំ ១៩៥១ ។ ការសុំច្បាប់បោះពុម្ពផ្សាយមានការលំបាកបំផុត ក្នុងជំនាន់នេះ ។ មុនឯករាជ្យ រហូតដល់ឆ្នាំ ១៩៥៤ ពុំមានរោងពុម្ពជាឯកជននៅស្រុកខ្មែរយើងទេ ។ រោងពុម្ពមានតែមួយគត់ដែលអាណានិគមដាក់ឱ្យ គឺរោងពុម្ព *ព្រះរាជទ្រព្យ* របស់ព្រះរាជវាំងតែប៉ុណ្ណោះ ។ រោងពុម្ពនៅកម្ពុជាចាប់មានការរីកចំរើនពីឆ្នាំ ១៩៥៤ រហូតដល់ឆ្នាំ ១៩៧៥ ដែលនាំឱ្យឃើញថាខ្មែរត្រូវការអាន និងមានអ្នកសរសេរនិពន្ធជាច្រើន ។ សៀវភៅជាច្រើនដែលមិនបានច្បាប់អនុញ្ញាតឱ្យបោះពុម្ពផ្សាយ ត្រូវរង់ចាំឆ្នាំ ១៩៧០ ទើបផ្សាយបាន ដូចជាសៀវភៅរបស់លោក *ប៊ុនច័ន្ទម៉ុល* ជាដើម ។ល។

យើងមិនចាំបាច់និយាយពីរយៈកាលពី៧៥-៧៨ និងពី៧៩ មកទល់ថ្ងៃនេះទេ ។ ទោះជាអ្នកនិពន្ធខ្មែរ ដែលខំសរសេរក្នុងក្តីអត់បាយយ៉ាងណា ក៏បរិយាកាសនៃអំណាចឃ្លានកុម្មុយនីស្ត

មិនអនុញ្ញាតឱ្យមានលទ្ធភាពបោះពុម្ពតាមសេរីបានដែរ ។ ជីវិត
អ្នកសារពត៌មានស្នេហាជាតិទាំងឡាយ ត្រូវទទួលការគំរាមកំ
ហែងដល់ជីវិត បាញ់សម្លាប់ ដូចជាលោក នន្ទចន្រ្ទ ជាដើម
ត្រូវបានបាញ់ស្លាប់នៅដើមខែកញ្ញាឆ្នាំ១៩៩៤ ដែលយើងបានឮ
ស្រាប់ ទាំងអស់គ្នា ។ ប្តឹង សម្លាប់អ្នកកាសែត មិនអស់ចិត្ត
អំណាចយួននៅភ្នំពេញប្តឹងសម្លុតម្ចាស់រោងពុម្ពនៅភ្នំពេញ មិន
ឱ្យបោះពុម្ពផ្សាយកាសែតស្នេហាជាតិ ។ ការរឹតត្បិតរោងពុម្ព
នៅកម្ពុជា ជាមធ្យោបាយមួយ ក្នុងនយោបាយយួន សម្លាប់
អក្សរជាតិខ្មែរ កាត់ផ្តាច់ការទាក់ទងរវាងបញ្ញវ័ន្តខ្មែរនិងប្រជា
រាស្រ្តខ្មែរនិងសម្លាប់គតិវិជ្ជាខ្មែរ ឱ្យខ្មែរនៅតែល្ងង់ខ្លៅ ដើម្បី
ងាយស្រួលក្នុងការបំបែកបំបាក់តទៅទៀត ។ ល្ងង់កាន់តែខ្លាំង
បែកបាក់គ្នាក៏កាន់តែខ្លាំង ។ នេះជានយោបាយយួនមួយយ៉ាង
ជាក់ស្តែងបំផុត ។ ហេតុនេះ ការខំសរសេរជាអក្សរខ្មែរជូន
ដល់ប្រជារាស្រ្តខ្មែរ ជូនដល់កូនខ្មែរ នៅតែជាភារកិច្ចមួយ
របស់បញ្ញវ័ន្តខ្មែរទំនើបដែលចាំបាច់ពាំនាំចំណេះវិជ្ជាពីបរទេស
មកជូនជាតិខ្លួន ។ បើយើងសរសេរតែជាអក្សរបរទេស ប្រជា
ពលរដ្ឋខ្មែរ កូនខ្មែរទូទៅពុំអាចឈោងយល់បានទាំងអស់គ្នាទេ
។ យើងនឹងវិលទៅសម័យអាណានិគមម្តងទៀត ។ នៅអាស៊ី
ទាល់តែក្រោយពីការបះបោររបស់ពួកតៃពីង នៅប្រទេសចិន
ដែលត្រូវពួកបស្ចឹមប្រទេសវាយបង្ក្រាប សម្លាប់អស់ពី៥០ ទៅ
១០០លាននាក់(១៧) ទើបជប៉ុនចាប់គិតថា ដើម្បីប្រយុទ្ធនឹង

មហាអំណាចបស្ចិមប្រទេសបានទាល់តែប្រើចំណេះបស្ចិមប្រទេស ។ ជប៉ុន គឺជាប្រទេសអាស៊ីទី១ មុនគេ ដែលយល់ការចាំបាច់ប្រើចំណេះពីបស្ចិមប្រទេសដើម្បីយកឈ្នះលើបស្ចិមប្រទេសបាន ។ ការអនុវត្តន៍ ប្រតិបត្តិ ផ្សព្វផ្សាយចំណេះពីបស្ចិមប្រទេសនេះ ធ្វើឡើងដោយស្តេច ម៉ីជី (Meiji) ក្នុងឆ្នាំ ១៨៦៨ ។ នៅឆ្នាំ ១៨៩៥ ជប៉ុនយកជ័យជំនះលើស្រុកចិន ធ្វើឱ្យចិនចាញ់ជប៉ុនរាប ។ ឆ្នាំ១៩០៥ ជប៉ុនវាយឈ្នះរុស្ស៊ី ។ ជប៉ុនហាក់បង្ហាញប្រាប់សកលលោកថា បស្ចិមប្រទេសមិនអាចឈ្នះគេរហូតបានទេ នៅលើផែនដី ។ រីឯប្រទេសចិន ចិនដើរយ៉ាងយឺតទៅរកការបកប្រែក្រោយជប៉ុន៣០ឆ្នាំ ។ ជប៉ុនបានលើកពាក្យស្លោកថា៖"*ចំណេះបស្ចិមប្រទេស ព្រលឹងជប៉ុន*" ។ ជប៉ុនបានធ្វើការបកប្រែយ៉ាងមមាញឹក ដើម្បីរៀនគំរូនៃវិជ្ជាបស្ចិមប្រទេស ។ សូមរំលឹកថា អានុភាពអារ៉ាប់ខ្លាំង ដោយសារអារ៉ាប់បានបកប្រែឯកសារក្រិក,ឯកសារ ចិន,ឯកសារសំស្ក្រឹតមកជាភាសាអារ៉ាប់មុនគេ ។ ជនជាតិអឺរ៉ុបបានចាប់ផ្តើមបង្កើនចំណេះដឹងរបស់ខ្លួនដោយចាប់បកប្រែឯកសារអារ៉ាប់-ក្រិក មកជាភាសាឡាតាំង រួចហើយបកប្រែពីភាសាឡាតាំង ទៅជាភាសាបារាំង,អង់គ្លេស,អាល្លឺម៉ង់ ។ល។ តាមប្រទេសនីមួយៗ ។ ការរីកចំរើននៃអារ្យធម៌នីមួយៗ តែងបានមកអំពីវិភាគទាននៃអារ្យធម៌ក្រៅ បូកនឹងការរក្សាព្រលឹងជាតិរបស់ខ្លួន ដែលចាក់ឫសលើពិសោធន៍នៃអតីតកាលរបស់ខ្លួន ។ អារ្យធម៌មកពី

ក្រៅ ផ្សាំលើដើមរបស់ជាតិដែលមានឫសកែវលើអតីតកាលចាស់យូរលង់ នាំឲ្យអារីយធម៌ជាតិចំរើនទៅមុខ ។ ប៉ុន្តែ បើយកទាំងមែក,ទាំងធាង,ទាំងឫសរបស់គេមកដាំលើដីខ្លួន ក្រែងឫសថ្មីមិនចាប់លើដីចាស់ ។ ម្ល៉េះហើយ ការស្គាល់អារីយធម៌ខ្លួនជ្រៅប្រាកដ ទើបអារីយធម៌ក្រៅមិនអាចមកគ្របសង្កត់លើអារីយធម៌ជាតិបាន ។ ការបកប្រែពីភាសាបរទេសមកជាភាសាជាតិនៅតែជាការចាំបាច់ក្នុងអភិវឌ្ឍន៍ប្រទេស ។

ប្រាជ្ញាតែឯកឯងជាការមិនគ្រប់គ្រាន់ឡើយ ។ យើងចាំបាច់ចាប់អារម្មណ៍អំពីសារៈសំខាន់នៃកេរ្តិ៍តក វប្បធម៌ អារីយធម៌ ដែលដូនតាយើងបានទុកឲ្យ ដោយលោកបានចំណាយកម្លាំងចិត្ត កម្លាំងកាយ ញើសឈាម ដើម្បីទុកបន្តដល់យើង ។ តើដូនតាយើងប៉ុន្មានសែន ប៉ុន្មានលាននាក់ ដែលបានលះបង់ជីវិតដើម្បីឲ្យកម្ពុជាយើងរស់? យើងត្រូវការចំណេះវិជ្ជាច្រើនផ្នែក ដែលជាកេរ្តិ៍ពីមនុស្សជាតិទាំងឡាយទុកឲ្យផែនដីតាំងពីប៉ុន្មានឆ្នាំកន្លងមកផង បូកនឹងចំណេះដូនតាយើងផង ។ បដិសេធមិនព្រមបូកបញ្ចូលវិជ្ជាសកលមកក្នុងវប្បធម៌ខ្លួន ក៏ជាការនាំឲ្យយើងខ្វះសេចក្តីចំរើនផង ការពារជាតិមិនបានផង ។ ប៉ុន្តែ បើយើងមានឫសរបស់ខ្លួនរឹងមាំហើយ យើងអាចយកមែកថ្មីមកផ្សាំឲ្យចេញជាផ្លែផ្កាបាន ។ ការយកចំណេះពីក្រៅទាមទារការត្រងយកចំណេះជ្រៅពិតប្រាកដ ចៀសវាងយកតែសំបកគេមកប្រើប្រាស់ ដែលអាចនាំឲ្យវិនាសដល់ស្រុកខ្លួន ។

ជាការគួរឱ្យសោកស្ដាយ គឺសៀវភៅដែលផ្សាយប្រវត្តិសាស្ត្រល្អ ផ្សាយវប្បធម៌ជ្រៅ នៅមានតែជាភាសាបរទេស ។ សៀវភៅសំខាន់ៗដែលបកប្រែមកជាភាសាខ្មែរ នៅមានចំនួនតិចបំផុត ។ គ្មានអ្វីជំនួសសំណេរបានទេ ក្នុងការផ្សព្វផ្សាយចំណេះទូទៅ ។ ការពិសោធន៍បង្រៀនតាមកោសល្យតាមទូរទស្សន៍នៅអាហ្វ្រិក បានបង្ហាញថា ទៅពុំបានឆ្ងាយទេ ក្នុងការអប់រំប្រជាជនដែលមិនចេះអានអក្សរ ដោយយកទូរទស្សន៍ជំនួសការអាន ។ យើងសូមដកស្រង់មតិអ្នកសារព័ត៌មានអឺរ៉ុប សរសេរក្នុង*ឡឺពង់* (Le point 19-25 Juin 1989) ថា៖ Les expériences de télévision pédagogiques effectuées en Afrique, il y a plusieurs années, sur des populations illettrées l'ont démontré: on ne peut pas trier, hiérarchiser les informations apportées par l'image si on ne possède pas déjà l'écrit, donc une pratique quotidienne de l'abstraction. នេះជាការបញ្ជាក់អំពីសារៈសំខាន់ ចាំបាច់នៃការចេះអាន ។

អ្នកចេះអាន មានទម្លាប់គិតស្រមៃច្រើន គឺគេអាចមើលភ្លឺ មើលជ្រៅ មើលមេឃ មើលឆ្ងាយតាមតួអក្សរបាន ។ គេមានទម្លាប់គិតតាមអរូបិយ ដូច្នេះធ្លាប់គិតជាប្រយោគ ។ សំណេរគឺជាមូលដ្ឋានចាំបាច់សំរាប់ការត្រិះរិះពិចារណាជ្រៅ របស់បុគ្គលម្នាក់ៗ ។ ការប្រឌិត បង្កើតគំនិតជ្រៅ គឺចេញពីបុគ្គលមុនគេ ។ ការបង្កើតថ្លៃប្រឌិតរបស់ប្រជាជននីមួយៗ ពុំអាច

ធ្វើបានដោយគ្មានឫសនៅក្នុងជាតិរបស់ខ្លួនទេ ។ បើគ្មានឫសគល់ខ្លួនឯង វប្បធម៌គេមកពីក្រៅខ្លាំងជាង និងនាំឱ្យបាត់ដើមកំណើតរបស់ខ្លួន ។ ប៉ុន្តែ វប្បធម៌មួយដែលបិទ រួញ គ្មានការទាក់ទងទៅក្រៅ ក៏នឹងត្រូវតែបាត់សូន្យជាពួកជនជាតិប៊ូស្មេននៅអាហ្វ្រិកខាងត្បូង ឬជនជាតិផ្សេងៗនៃសង្គមអាម៉ាហ្សូន៍ នៅអាមេរិកខាងត្បូងដូច្នេះដែរ ។ ការប្រយុទ្ធគ្នារវាងវប្បធម៌ដើម និងវប្បធម៌ក្រៅនេះ លោក*ឡេវីស្ត្រូស* (Lewis Strauss) ធ្លាប់បានសរសេរបកស្រាយនៅយូណេស្កូក្នុងឆ្នាំ១៩៨៤(១៨) ថា៖ ***"វប្បធម៌ណាដែលនៅឯកោស្ងាត់ស្ងៀម បិទជិតតែលើខ្លួនឯង រីងរៃតែងងាប់ស្លាប់"*** ។ ហេតុនេះហើយបានជាជប៉ុនលើកពាក្យស្លោកថា៖ ***"ចំណេះវិជ្ជាបរទេស ព្រលឹងជប៉ុន"*** ។

ពាក្យថា អ្នកចេះ អ្នកមានគតិៈ ពុំមែនមានន័យថា អ្នកទាំងអស់នេះសុទ្ធតែជាអ្នកជាតិនិយមទាំងអស់ទេ ។ ប៉ុន្តែ គឺនៅក្នុងចំណោមអ្នកមានគតិៈវិជ្ជាទាំងឡាយនេះហើយ ដែលលេចចេញអ្នកជាតិនិយម លេចចេញអ្នកដឹកនាំជាតិ ដឹកនាំការតស៊ូក្នុងជាតិរបស់យើង ។ ក្នុងចំណោមអ្នកមានគតិៈវិជ្ជានេះ កម្ពុជាយើងត្រូវការឱ្យមាននារី ព្រោះគេទាំងឡាយតំណាងឱ្យមនុស្ស ៦០% ក្នុងជាតិរបស់យើងបច្ចុប្បន្ន ។ គឺដោយសារសង្គ្រាមយួនជិះជាន់ជាង១៧ឆ្នាំនេះ បុរសខ្មែរជាច្រើន ត្រូវបាត់បង់ទៅ ។ ម្ល៉ោះហើយ នារីខ្មែរជាច្រើនត្រូវរ៉ាប់រងទាំងស្រុង ជំនួសប្ដី ជំនួសឪពុក ជំនួសប្រុសក្នុងគ្រួសារនីមួយៗ ។ គឺនារី

នេះហើយជាអ្នកចិញ្ចឹម អប់រំកូនផ្ទាល់ ។ ការចេះដឹងមានតិះ វិជ្ជារបស់គេទាំងឡាយ ជាការចាំបាច់ក្នុងសង្គមខ្មែរយើង។ តើឱ្យកូនខ្មែរមានមោទនភាពលើជាតិខ្លួន លើស្រុកខ្លួនបានទេ បើគេទាំងឡាយគ្មានមោទនភាពលើម្ដាយរបស់គេ? ការពិសោធន៍សកលលោកបានបង្ហាញច្បាស់ថា ការបង្ហាត់អក្សរដល់នារី បាននាំប្រទេសជាច្រើន ឱ្យឈានមួយជំហាន ចេញពីភាពក្រខ្សត់ បន្ថយចំនួនទារកស្លាប់ កុមារស្លាប់ ព្រមទាំងបន្ថយ ជំងឺកំណាចផ្សេងៗទៀត ។ បើម្ដាយចេះ កូនអាចរៀនបានកាន់តែរហ័ស និងច្រើនឡើង គ្រួសារអាចមានជីវភាពធូរធារ ។ ប៉ុន្តែជាអកុសល ការផ្តល់ចំណេះដល់នារី នៅតែពុំទាន់ប្រើមធ្យោបាយគ្រប់គ្រាន់ទេក្នុងប្រទេសក្រីក្រ ជាពិសេសទៅទៀត ប្រទេសយើងដែលត្រូវឃ្លនជិះជាន់រាល់ថ្ងៃនេះ នារីខ្មែរជំពាក់ប្រយុទ្ធរកច្រកផ្គាំងគ្រួសារផង ប្រយុទ្ធរកសន្តិសុខផង ។ តើក្នុងមួយថ្ងៃគេនៅសល់ប៉ុន្មានទាទីសំរាប់រៀនខ្លួនឯងផង បង្រៀនកូនផង? សង្គ្រាមឃ្លនជិះជាន់ខ្មែរនៅចុងសតវត្សរ៍ទី២០នេះ បានធ្វើឱ្យនារីខ្មែរជាច្រើនត្រូវស្ថិតនៅក្នុងសភាពមិនចេះអក្សរ ។ ប៉ុន្តែនៅក្នុងសង្គ្រាមនេះដែរ នារីខ្មែរមួយភាគធំ ដែលបានលត់ដំនឿល ប្រយុទ្ធរករស់ផង ហាត់រៀនខ្លួនឯងផង ចិញ្ចឹមកូនផង ដើម្បីរក្សាវប្បធម៌ខ្លួនជាខ្មែរ អប់រំកូនឱ្យនៅជាខ្មែរ ប្រយុទ្ធឥតឈប់ឈរដើម្បីឱ្យកូនបានរៀនសូត្រ ។ ប្រទេសជឿនលឿន ទាមទារនារីមានចំណេះវិជ្ជា ដូចពាក្យខ្មែរតែងនិយាយ

ថា *"សំណាបយោងដី ស្រីយោងប្រុស"* ។ ចុះប្រទេសយើងដែលមាននារី៦០% នេះ បញ្ហានារីជាបញ្ហា៦០% នៃប្រទេសដែលយើងចាំបាច់ចាប់អារម្មណ៍ឱ្យដល់កំរិត ឥតនិយាយស្រាលបានទេ ។ មេរៀនបាត់ទឹកដី នាំយើងទៅដល់មេរៀននៃការបែកបាក់ នាំយើងទៅដល់ឫសគល់នៃការបែកបាក់ នាំយើងទៅដល់ការចាំបាច់អភិវឌ្ឍន៍ខាងការអប់រំទូទៅ ។ *"ប្រជាជនខានចំណេះ ប្រទេសពិតជាមិនធ្ទុំគេទេ"* ។

ដើម្បីចៀសវាងការបាត់ទឹកដីនេះ ប្រវត្តិព្រំដែនយើងខាងលើហាក់ប្រាប់យើង ហើយប្រាប់ទៀតថា គ្មានបរទេសណាស្រឡាញ់ខ្មែរជាងខ្មែរបានទេ ។ គ្មានបរទេសណាអាចមកការពារព្រំដែនខ្មែរជំនួសខ្មែរទេ ។ ទាំងពិសោធន៍ចាស់ ទាំងពិសោធន៍ថ្មី ទាំងប្រវត្តិចាស់ ទាំងប្រវត្តិថ្មី គ្មានអ្វីប្រែប្រួលពីសច្ចធម៌នេះទេ ។ អំណាចកាន់កាប់ស្រុកយើងបច្ចុប្បន្ន ដែលរៀបចំដាក់ឱ្យដោយមហាអំណាចបរទេសនិងយួន គឺជាអំណាចមួយ ដែលគេដាក់ឱ្យដោយប្រមាថមើលងាយយ៉ាងធ្ងន់ណាស់លើឆន្ទៈរបស់ប្រជាជាតិខ្មែរ ។ ព្រះមហាក្សត្រឥតអំណាច ប្រជារាស្ត្រឥតសេរីភាព ។ អំណាចដែលគេដាក់នៅកម្ពុជាយើងថ្ងៃនេះ គឺជាអំណាចសំរាប់បង្ក្រាបប្រជារាស្ត្រខ្មែរឱ្យលុតជង្គង់ទទួលនឹមផ្តាច់ការកុម្មុយនិស្ត ដែលដាក់ដោយហាណូយតែប៉ុណ្ណោះ ។ អំណាចនេះឥតសំរាប់ជួយខ្មែរឱ្យរំដោះខ្លួនពីនឹមយួនទេ គឺជាអំណាចមួយសំរាប់យួនលេបព្រំដែនខ្មែរតែប៉ុណ្ណោះ

។ គេតែងនិយាយថា ទាល់តែជួយខ្លួនឯងសិន ទើបព្រះលោកជួយ ។

រដ្ឋអំណាចពិតប្រាកដសំរាប់ធានាជីវិតទឹកដី ធានាសេរីភាពប្រជាធិបតេយ្យ ការពារប្រជាជន កុំឱ្យបរទេសប្រើញបាន ការពារភាពថ្លៃថ្នូរបាន គឺជារដ្ឋអំណាចដែលចេញមកពីផ្លូវតែមួយគត់ គឺការតស៊ូរបស់ប្រជាជនខ្មែរ ។ នេះជាសច្ចធម៌នៅលើសកលលោកទាំងមូល ។ លោក ឡេវីមុមហ្វ័រ (Lewis Mummford) អ្នកស្រាវជ្រាវម្នាក់សរសេរថា៖ "*គេអាចនឹងឃើញបានយ៉ាងច្បាស់នៅសម័យនេះ នូវទ្រឹស្តីមួយដែលនិយាយថា ជីវិតជាការចំរាញ់ជ្រើសរើសដោយធម្មជាតិ* (Sélection naturelle) ។ *យើងបានឃើញថា នៅក្នុងរយៈប្រាំ-ប្រាំមួយពាន់ឆ្នាំចុងក្រោយនេះ ប្រជាជនណាដែលស្លូតជាងគេ រាក់ទាក់រាបសារជាងគេ ដែលត្រូវគេកំទេច ហើយត្រូវផុតពូជអស់ពីផែនដីបន្តិចម្តងៗ ។ រីឯពួកក្រុមដែលចូលចិត្តធ្វើចម្បាំងវិញ នេះតែកើតកើនឡើង ផ្លាស់គ្នា បន្តវេនគ្នា ក្លាយទៅជាអ្នកកាន់ចន្លុះអរិយធម៌*" ។ ជាភាសាបារាំង ៖ « Du moins pourra-t-on voir à cette occasion s'appliquer dans toute sa rigueur la théorie de la sélection naturelle; car au cours des cinq ou six derniers millénaires, les peuples les plus doux, les plus aimables et les plus accueillants ont été exterminés ou condamnés à disparaître, tandis que prospéraient les groupements les plus belliqueux qui relevaient tour à tour le

flambeau civilisateur.» (Lewis Mumford: "La Cité à travers l'histoire", Editions du Seuil, 1964, p.59).

តើប្រជាជនខ្មែរនៅតែទុកខ្លួនជាមនុស្សល្អ សុភាព រាបសារ ចង់នរណាថាអ្វី ឱ្យអ្វី ក៏នៅតែញញឹមទទួលជានិច្ចឬ? ឬមួយបើប៉ះ ឬមួយចេះតែទទួល? ឆាលដឺហ្គោល (Charles De Gaule)សរសេរថា៖ *"ជីវិតគឺជាជីវិត! ជីវិតជាការតស៊ូ! ជីវិតជាតិក៏ដូចជីវិតមនុស្សដែរ"*. ។



# ៥

# អំពីប្រពៃណីយោធា

មេរៀននៃប្រវត្តិព្រំដែនទឹកដី ជាមេរៀនរបស់កងទ័ព ។ ទឹកដីមួយដែលឥតកងទ័ពការពារ ថែរក្សា ទឹកដីនោះនឹងក្លាយទៅជាសម្បត្តិកម្មសិទ្ធិរបស់អ្នកដទៃណាដែលមានកងទ័ពដោយចៀសមិនផុត ។ ដូច្នេះ បើគ្មានកងទ័ពការពារទឹកដី ទប់ការឈ្លានពានទេ ទឹកដីនេះត្រូវតែបាត់ ។ ហៅថាកងទ័ពរបស់ជាតិ លុះត្រាតែកងទ័ពនោះ អាចប្រយុទ្ធការពារការឈ្លានពានព្រំដែនរបស់ខ្លួនពីសំណាក់បរទេសបាន ។ កងទ័ពបែបនេះទាមទារការលត់ដំក្នុងការតស៊ូរបស់ប្រជាជន ។ កងទ័ពដែលហៅថាកងទ័ពជាតិ ចាំបាច់ត្រូវមានប្រពៃណីយោធាជាតិរបស់

ខ្លួន ។ ប្រពៃណីយោធាជាតិ គឺជាគ្រឹះកំផែងការពារជាតិ ។ គេមិនអាចនិយាយអំពីកិច្ចការពារជាតិ ដោយឥតគិតពីបញ្ហាយោធាបានទេ ។ ប្រពៃណីយោធា ជាគ្រឿងតឹករបស់ជាតិ ។ ឈើរឈីល (Churchill) មេទ័ពអង់គ្លេស ដែលឡើងកាន់អំណាចក្នុងសម័យធ្វើសង្គ្រាមប្រឆាំង ហ៊ីត្លែរ ឆ្នាំ១៩៤០ តែងនិយាយថា៖ "*គេសុខចិត្តចាញ់សង្គ្រាមមួយបាន តែចាញ់ប្រពៃណីយោធាមិនបានជាដាច់ខាត ព្រោះគេត្រូវការប្រយុទ្ធរាប់សតវត្សរ៍ ដើម្បីយកដំប្រពៃណីយោធារបស់ជាតិនីមួយៗ*" ។

តើនៅកម្ពុជាយើង មានប្រពៃណីយោធាឬទេ ? យើងឆ្លើយថា ប្រពៃណីយោធានៅរស់រវើកនាជនបទខ្មែរ ។ ខ្មែរជំនាន់នេះនៅចាំច្បាស់ អំពីជីដូនជីតា ជីទួតរបស់ខ្លួន ដែលធ្លាប់ច្បាំងដេញយួនឆ្នាំ១៨៣៥-១៨៤៨ ។ អដ្ឋិធាតុរបស់ជីទួតយើងទាំងនេះបានត្រូវតម្កល់នៅភ្នំចិតរស ក្រុងឧត្តុង្គ ជុំវិញព្រះរាជចេតិយ ដោយព្រះបាទអង្គឌួង ដើម្បីជាការដឹងគុណដល់វីរៈបុរសជាតិខ្មែរទាំងឡាយ ។ មុនឆ្នាំ ១៩៧០ ចេតិយទាំងនេះតែងតែត្រូវបានថែទាំរក្សា បោសសំអាតដោយកូនចៅជានិច្ច ។ ក្រៅពីចេតិយរបស់មេទ័ពខ្មែរទាំងនេះ ភស្តុតាងនៃសំណល់ប្រពៃណីយោធាខ្មែរ គឺដាវ ។ ប្រុសខ្មែរតែងចេះកាន់ដាវបន្តគ្នាពីឪពុកទៅកូនប្រុស នៅក្នុងគ្រួសារនីមួយៗ ។ ក្នុងប្រពៃណីអាពាហ៍ពិពាហ៍ខ្មែរ កូនប្រុសត្រូវសំពះគ្រូដាវ ក្នុងនាទីខ្លួនជាអ្នកការពារគ្រួសារ ការពារត្រកូល និងទឹកដី ។

នៅលើសកលលោក ហាក់មានតែខ្មែរយើងទេ ដែលមានប្រពៃណីនេះ ក្នុងពិធីអាពាហ៍ពិពាហ៍ ។ អំពីកិច្ចគោរពដាវនេះ ឯកសារលោក *ឌុយហ្វូស* (Dufosse)(១៥) បានបញ្ជាក់ ឱ្យយើងដឹងថា នៅភូមិប្រាសាទ ចម្ងាយពីរគីឡូម៉ែត្រប៉ែកខាងកើតស្រុកបារាយណ៍ ខេត្តកំពង់ធំ មានដាវទិព្វពីរ ហៅថាព្រះខ័ន្ធទិព្វ ដែលគេតែងទៅថ្វាយបង្គំ ធ្វើកិច្ចគោរពរៀងរាល់ឆ្នាំ ។ ព្រះខ័ន្ធទិព្វភូមិប្រាសាទ តែងតែត្រូវដង្ហែដឹកយកទៅភ្នំពេញជារៀងរាល់ឆ្នាំ ថ្វាយព្រះមហាក្សត្រ ព្រោះឮពិធីថ្វាយបង្គំដាវ ។ លុះដល់ឆ្នាំ១៩១៦ មានវិកវរចលាចលខ្លាំងក្នុងប្រទេស ហើយលេចឮថា ព្រះខ័ន្ធទិព្វត្រូវគេលួចបាត់ ។ ព្រះមហាក្សត្រនៅភ្នំពេញ ច្រួលច្របល់យ៉ាងខ្លាំង បានចាត់ឱ្យធ្វើការអង្កេត ។ គេបានឃើញថា ព្រះខ័ន្ធត្រូវបាត់មែន ។ ព្រះខ័ន្ធទាំងពីរនេះពិតជាដាវរបស់មេទ័ពខ្មែរដ៏ខ្លាំងពូកែពីរនាក់ដែលបានប្រើប្រាស់តស៊ូធ្វើចម្បាំងដេញយួនពីដីខ្មែរ ឆ្នាំ១៨៣៥-១៨៤៨ ។ ក៏ប៉ុន្តែ ជាការគួរឱ្យសោកស្តាយ គឺឈ្មោះវីរបុរសទាំងពីរជាម្ចាស់ដាវភូមិប្រាសាទនេះ ត្រូវគេបំភ្លេចជាស្ថាពរ ។ ក្នុងព្រះរាជពង្សាវតារខ្មែរយើង តែងជួបប្រទះឈ្មោះវីរៈមេទ័ពខ្មែរជាច្រើនដូចជា ឧកញ៉ា*ទេព* បងប្អូនឧកញ៉ា*ឌូ* និង *ម៉ឹម* ធម្មា*ឌុក* ឧកញ៉ារាជតេជៈ*ណង់ណឹម* ឧកញ៉ា*កាយ* ឧកញ៉ា*ឡាយ* ។ល។ តើឈ្មោះទាំងនេះបានត្រូវចារទុកក្នុងមហាចេតិយ នៃក្រុងឧត្តុង្គឬទេ? យើងសូមទុកឱ្យអ្នកប្រវត្តិសាស្ត្រយើងធ្វើការស្រាវជ្រាវ

បំភ្លឺកូនខ្មែរតទៅទៀត ។

ប្រពៃណីយោធាដ៏រស់រវើកមួយទៀត គឺរឿងអ្នកតាឃ្លាំងមឿង ។ រឿងអ្នកតាឃ្លាំងមឿងជារឿងរបស់យោធា ។ រឿងនេះស្ថិតនៅក្នុងដួងវិញ្ញាណកូនខ្មែរ មកទល់បច្ចុប្បន្ន មិនសាបរលាប ដោយឱ្យអត្ថន័យថា៖ ***"អ្នកណាការពារប្រពៃណីរបស់បុព្វបុរសខ្លួន និងគោរពវិញ្ញាណក្ខ័ន្ធរបស់វីរបុរស អ្នកនោះនឹងមានទាំងយសទាំងទ្រព្យជាពុំខាន ។"*** មានតែស្នាដៃប្រយុទ្ធរាប់មិនអស់នេះហើយ ដែលការពារជីវិតស្រុកយើងឱ្យបានគង់វង្សដល់សព្វថ្ងៃ ។ ពាក្យអ្នកប្រវត្តិសាស្ត្រតែងនិយាយថា៖ ***"ដីរបស់មាតុភូមិយើង គឺជាដីរបស់អ្នកតែកឈាមទៅទាំងឡាយ"*** ។ ហេតុនេះហើយ បានជាគ្រប់ជាតិទាំងអស់ គេតែងតែលើកវិមាន សង់ជូនដល់វិញ្ញាណក្ខ័ន្ធវីរបុរស ដែលបានពលីជីវិតការពារទឹកដី ។ ជាតិធំៗទាំងឡាយ មិនដែលបែរខ្នងដាក់ប្រពៃណីយោធារបស់គេទេ ដូចឈើរឈីលនិយាយថា ***"សុខចិត្តចាញ់សង្គ្រាមមួយ តែមិនឱ្យបាត់ប្រពៃណីយោធាទេ"*** ។ ដើម្បីលត់ដំប្រពៃណីយោធានីមួយៗ គេត្រូវការពេលវេលាច្រើនណាស់ គឺរាប់សតវត្សរ៍ ។ នៅជនបទ ខ្មែរភាគច្រើនបានរក្សាប្រពៃណីយោធាតាំងពីដូនតាមុនសម័យអង្គរមក ។ ប្រពៃណីនេះ បន្តតារហូតដល់ ***ជ័យវរ្ម័នទី៧*** បន្តដល់អ្នកតា***ឃ្លាំងមឿង*** បន្តដល់***អង្គឌួង ឧកញ៉ាឥន*** រហូតដល់មេទ័ព***កែវ*** ឆ្នាំ១៨៣៤-១៨៤៨-១៨៥០ បន្តដល់ការបះប្រឆាំងនឹងអាណា

និគម ១៨៨៥_១៨៨៦ ហើយក៏នៅតែបន្តរស់អ្នកតស៊ូរំដោះស្រុកពីឃ្លួនបច្ចុប្បន្ន ។ ដរាបណាឈាមអ្នកឡាំងនៅតែហូរក្នុងសរសៃបេះដូងរបស់កូនខ្មែរ ដរាបនោះជាតិខ្មែរនឹងនៅតែមិនអាចរំលាយបានទេ ។ អ្នកឡាំង គឺអ្នកប្រយុទ្ធ ប្រយុទ្ធលើគ្រប់សមរភូមិ ។ ហៅថាយោធាជាតិបាន លុះត្រាណាតែយោធានោះ ជាឧបករណ៍សំរាប់បំរើយុទ្ធសាស្ត្រនយោបាយការពារជាតិរបស់ប្រទេសខ្លួនក្នុងគ្រប់កាលៈទេសៈ ។ បើយោធាមិនទៅការពារទឹកដីព្រំដែនដែលឈ្លានពានដោយបរទេសទេ យោធានេះពុំមែនហៅថាយោធាជាតិបានទេ ។

ប៉ុន្តែ ប្រពៃណីយោធាសុទ្ធសាធ ពុំទាន់ជាការគ្រប់គ្រាន់ឡើយ ។ លក្ខណៈសម្បត្តិថ្មី បច្ចេកទេសអាវុធទំនើបថ្មី ទាមទារការបត់បែនក្នុងបែបបទប្រយុទ្ធជានិច្ច ។ ប្រពៃណីបូកនឹងបច្ចេកទេសថ្មី បូកនឹងមាគ៌ានយោបាយមួយត្រឹមត្រូវ ជានយោបាយជាតិ ទើបយើងឈានទៅរកជ័យជំនះបាន។ ដើម្បីលើកដំកើងប្រពៃណីយោធារបស់ជាតិខ្លួនបាន ការស្រាវជ្រាវគាស់កកាយលើប្រវត្តិសាស្ត្រយោធារបស់ប្រទេសយើង ជាការចាំបាច់ ។ ម្ល៉ោះហើយវិជ្ជាស្ថានស្រាវជ្រាវប្រវត្តិសាស្ត្រ ជាការចាំបាច់បន្ទាន់មួយ ដើម្បីស្វែងរកវីរភាពពិតរបស់វីរៈបុរសយើងមកប្រាប់កូនចៅយើង ឱ្យគេទាំងឡាយមានមោទនៈភាព មានការទុកចិត្តលើកម្លាំងជាតិពិតរបស់ខ្លួន ដើម្បីកុំឱ្យបរទេសនិងខ្មាំងសត្រូវគេសរសេរជីកកប់បំបាត់វីរៈបុរសរបស់យើង បំបាត់

អត្តភាព បំបាត់កេរ្តិ៍ឈ្មោះជាអ្នកថ្លៃថ្នូររបស់ដូនតាយើង។ នេះជាភារៈកិច្ចដ៏ឧត្តុងឧត្តមរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប របស់អ្នកដឹកនាំប្រទេស និងជាពិសេសរបស់បញ្ញាវ័ន្តខ្មែរទាំងឡាយ ។



## ៦

# ទស្សនៈយើង ទស្សនៈគេ លើប្រវត្តិសាស្ត្រយើង

***១-អំពីប្រវត្តិឈ្មោះយួន៖*** យើងចាំបាច់លើកពាក្យ "យួន" យកមកបញ្ជាក់ឡើងវិញ ព្រោះពាក្យថា "យួន" នេះបានត្រូវគេលើកយកមកចោទ បិទមាត់ខ្មែរ នៅឆ្នាំ ១៩៩២ ថាខ្មែរពូជសាសន៍និយម កាលណាខ្មែរហៅយួនដែលមកជិះជាន់ខ្មែរ នៅលើស្រុកខ្មែរថា យួន ។ នៅឆ្នាំ ១៩៩២ អ៊ុនតាក់បានចេញច្បាប់ចាប់ចងខ្មែរណាដែលហ៊ានប្រើពាក្យនេះ ។

មុនឆ្នាំ ១៨០០ ស្រុកយួនគ្មានទំហំដូចបច្ចុប្បន្ននេះទេ ។ មុននឹងដាក់ឈ្មោះថា វៀតណាម ជនជាតិយួនរស់នៅក្នុងខេត្ត

មួយខាងត្បូងប្រទេសចិនដែលមានឈ្មោះថា អាណ្ណាម ។ អាណ្ណាមមកពីពាក្យថា"អាន" ប្រែថាសន្តិភាព បូកពាក្យ"ណាម" ប្រែថាខាងត្បូង គឺខាងត្បូងសន្តិភាពរបស់ប្រទេសចិន ។ នៅឆ្នាំ ១៨០២ ស្ដេចយួនម្នាក់ឈ្មោះ យ៉ាឡុង បានមកសុំជំនួយពីស្ដេចខ្មែរ និងសុំជំនួយទ័ពបារាំង ដែលនៅក្រោមបញ្ជាការម៉ុងសេញ៉ោរពីញ៉ូដឺបេអែន (Monseigneur De Béhaine) និងអេវែកអាដ្រង់ (Evêque d'Adran) ដើម្បីយកអំណាចសោយរាជ្យនៅក្រុងហ្វេ ។ ដល់ឆ្នាំ ១៨០៤ យ៉ាឡុងក៏បានទទួលការតែងតាំងឱ្យកាន់អំណាច (Investiture) ពីអធិរាជចិន ដែលបានឱ្យឈ្មោះទៅយួននៅពេលនោះថា យេ-ណាន់ ជំនួសអាណ្ណាមវិញ ។ ពាក្យយេ-ណាន់ សរសេរតាមកុកង៉ឺថា វៀតណាម ព្រោះ "វ" យួនមិនអានថា "វ" ទេ គេអានថា "យ" គឺយៀកណាម ។ សូមរំលឹកថាអក្សរយួនដើម គឺអក្សរចិនកុកង៉ឺ ដែលបារាំងបានធ្វើរ៉ូម៉ានីយកម្មនៅឆ្នាំ ១៦៥០ ដើម្បីជំនួសអក្សរចិន ។ អក្សរយួនរ៉ូម៉ានីយកម្មនេះ ទើបតែនឹងប្រើប្រាស់ដោយយួនខ្លួនឯង នៅជំនាន់អាណានិគមបារាំងហើយទេ ។ ការបោះបង់ចោលអក្សរចិននេះ នាំឱ្យយួនផ្ដាច់ពីចិនខាងផ្នែកវប្បធម៌អក្សរសាស្ត្រ ។ យួនតែងហៅខ្លួនគេថា ដៃវៀត (ដៃ-តៃ-ធំ) គឺវៀតធំ ។ រីឯឈ្មោះថាវៀតណាមនេះ គេប្រើឡើងវិញនៅក្រោយសង្គ្រាមលោកលើកទី២ហើយទេ ។

តើពាក្យ "យួន" ចេញមកពីណា? យួនក្លាយមកពីពាក្យ

"យេ" គឺជនជាតិ យេ ដែលរស់នៅខាងត្បូងស្រុកចិន គឺនៅតុងកឹងដែលសព្វថ្ងៃហៅថា ហាណូយ ។ ចាមនៅប្រទេសចំប៉ាជាជាតិដែលរស់នៅជាប់របងព្រំដែនជាមួយពួកយេមុនគេ ។ ចាមក៏តែងហៅពួកនេះថា"យួន" ដែលក្លាយមកពីហៅយេមិនច្បាស់ ។ ខ្មែរយើងនៅឆ្ងាយពីយួនជាងចាម ក៏ស្គាល់ពាក្យនេះតាមរយៈចាម ។ សៀមក៏បន្តហៅយួនថា យួន ដូចចាម ដូចខ្មែរដែរ ។ ពាក្យយួននេះពុំមានអ្វីជាពាក្យសំរាប់បន្ថោកបន្ទាបប្រកាន់ពូជសាសន៍អ្វីទេ ។ ក៏ប៉ុន្តែ ដល់យួនដែលចូលមកជិះជាន់ខ្មែរ ចង់ធ្វើម្ចាស់លើដីខ្មែរមិនចង់ទៅស្រុកខ្លួនវិញ ក៏យកលេសបិទមាត់ខ្មែរកុំឱ្យបរិហារការពិត ស៊ីគ្រលំឱ្យអ៊ិនតាក់ចេញច្បាប់ហាមខ្មែរ មិនឱ្យហៅខ្លួនថាយួននៅឆ្នាំ ១៩៨២ ។ បើចង់និយាយពីពាក្យសំរាប់បន្ថោកបន្ទាប ជេរជនជាតិឈ្លានពានពីទិសខាងកើតនេះវិញ ពុំមែនពាក្យយួននេះទេ ។ ខ្មែរដែលស្អប់មេជិះជាន់ឈ្លានពានតែងប្រើពាក្យ "អាស្រកីដូង អាកន្ទុប ឬយួនកំពប់តែអុង ។ល។" តើប្រជាជនបារាំង ធ្លាប់ប្រើពាក្យអ្វីខ្លះសំរាប់ហៅពួកអាល្លឺម៉ង់ ពេលហ៊ីត្លែរចូលត្រួតត្រាឈ្លានពានបារាំងនៅក្នុងសង្គ្រាមលោកលើកទី២? មានតែក្តីល្ងិតល្ងង់លើប្រវត្តិសាស្ត្រទេ ទើបអាចទទួលយល់តាមពួកគេថាពាក្យ"យួន" ជាពូជសាសន៍និយម ។ គោដំបៅខ្នង ក្អែកហើររំលង រំសាយកន្ទុយ ។

## ២-គំនិតនិក្ខេបបទ ដែលនិយាយថា កម្ពុជាជាប្រទេស ចំណុះក្រុងហ្វេ មុនពេលបារាំងមកដល់កូសាំងស៊ីន

គំនិតនេះ ហាក់បានត្រូវបដិសេធយ៉ាងច្បាស់លាស់ណាស់ នៅក្នុងអត្ថបទជាភស្តុតាងរបស់លោក ម៉ក់ភៀន និងលោក ឡាម៉ង់ (Lamant) ដែលយើងបានដកស្រង់នៅខាងដើម ។ តើគេអះអាងនិក្ខេបបទថា ខ្មែរចំណុះក្រុងហ្វេ ដោយប្រើអ្វីជាសំអាង? គេយកត្រាដែលស្ដេចយួនថ្វាយមកព្រះបាទ អង្គឌួង នៅពេលអភិសេកសោយរាជ្យថ្ងៃ ៨ មិនា ១៨៤៨ ថាជាភស្តុតាងនៃការចំណុះរបស់ខ្មែរ ។ យួនខំយកត្រាមកថ្វាយមែនតែអង្គឌួង មិនដែលប្រើប្រាស់ត្រាយួននេះម្ដងណាឡើយ ក្នុងកិច្ចការរាជការខ្មែរ ។ ការនេះជាការផ្ទុយស្រឡះពី យ៉ាឡុង ដែលប្រើត្រាស្ដេចចិនប្រទានឱ្យ ក្នុងកិច្ចការយួន ព្រោះយ៉ាឡុងចំណុះស្ដេចចិន ។ នេះជាពិធីការទេ ។ ក៏ប៉ុន្តែការពិតទៅភាពចំណុះប្រទេសមួយពុំមែនស្ថិតនៅលើការឱ្យត្រាជាអនុស្សាវរីយមួយបានទេ ។ ដើម្បីឱ្យប្រទេសណាមួយចំណុះខ្លួនបានលុះត្រាតែមានកម្លាំងទ័ពគ្រប់គ្រាន់ ។ ការឱ្យត្រាមួយ ហៅថាដាក់កម្ពុជាចំណុះយួនពេលនោះ ជាការមិនគ្រប់គ្រាន់ជាដាច់ខាត ។ គេនិយមប្រើភស្តុតាងនេះ ដើម្បីឱ្យហេតុឱ្យផលទៅអាណានិគមតែប៉ុណ្ណោះ ។ គេចង់បង្ហាញ និងបញ្ចូលក្នុងខួរក្បាលយើងថា បើកុំតែ"លោកធំ"អាណានិគមបារាំងមកដល់ ខ្មែរមុខតែត្រូវចំណុះយួនជារៀងរហូត ។ នេះហើយចំរៀង

ដែលគេដាក់ថែងថា "ឱស្វាយទាំងជួរ លោកដាំទុកក្បែរ..." ។

យើងដឹងច្បាស់ថា នៅឆ្នាំ ១៨៥៩ ព្រះបាទ*អង្គឌួង* បាន បញ្ជូនកងពលរបស់លោកឧកញ៉ា*រាជសិទ្ធិភ័យ* ទៅវាយដណ្តើម យកខេត្តទ្រាំងត្រើយត្បូង (តំបន់កម្ពុជាក្រោមបច្ចុប្បន្ន) ពីយួន មកវិញ ពេលដែលទ័ពបារាំងទើបនឹងដាក់ជើងដល់សណ្តរមេ គង្គ(១១) ។ គេតែងនិយាយថា យួនអ្នកបកប្រែដំបូង ពេល ជូនបារាំងមកដីខ្មែរម្តងៗ វាភ័យខ្លាចអ្នកស្រុកខ្មែរណាស់ ។ ហេតុនេះ ក្នុងសម័យអង្គឌួងមុនបារាំងចូលមក(១៨៦៣) ភស្តុ តាងយ៉ាងច្រើនបង្ហាញថា ខ្មែរជាអត្តបញ្ហាការលើទឹកដីខ្លួន ពុំ មានចំណុះស្តេចក្រុងហ្វេទេ ។ ផ្ទុយទៅវិញ យួនក្រុងហ្វេ ជា ចំណុះស្រុកចិនពិតមែន ព្រោះពេលយ៉ាឡុងសោយរាជ្យ ស្តេច ចិនបានប្រគល់ត្រាឱ្យយ៉ាឡុងប្រើប្រាស់ ក្នុងកិច្ចការរាជការរបស់ យួនរហូតដល់សម័យទូឌុច ។ ទាល់តែអាណានិគមបារាំងមក ច្បាំងវាយដណ្តើមយកតុងកឹងផ្តាច់ពីចិន ទើបយួនឈប់ចំណុះ ចិន រើបរជាចំណុះបារាំងវិញតែប៉ុណ្ណោះ ។

ជាការខុសស្រឡះពីបញ្ហាខ្មែរ ។ ខ្មែរត្រូវបារាំងប្រើកម្លាំង ទ័ពដាក់ប្រទេសខ្មែរក្រោមអាណាព្យាបាលគេ ។ តែមុននឹង បារាំងមកដល់ ខ្មែរឯករាជ្យ ឥតចំណុះយួនទេ ។

តើបារាំងច្បាំងនឹងចិនយ៉ាងណាខ្លះ ដើម្បីផ្តាច់តុងកឹងពីចិន ហើយបង្កើតជាស្រុកយួនដល់សព្វថ្ងៃ? ថ្ងៃ២៣សីហា ១៨៨៣ បារាំងបានបង្ខំដាក់អាណាព្យាបាល ត្រួតត្រាលើស្តេចអាណ្ណាម

ឈ្មោះទូទុច ដែលជាស្តេចចំណុះអាណាចក្រចិន ។ ពេលនោះ យួនចង់ទប់ទល់បារាំង រដ្ឋាភិបាលវៀតណាមបានទៅសុំអន្តរាគមពីកងទ័ពចិន ។ ចម្បាំងបារាំងនិងចិននៅពេលនោះ មានការផ្ទុះអាវុធប្រយុទ្ធគ្នាយ៉ាងខ្លាំង ។ ផ្នែកជើងទឹក មេទ័ពបារាំងឈ្មោះ អាមេរ៉ាល់គួរបេ (Amiral Courbet) បញ្ជាចម្បាំងនៅកោះហ្វរម៉ូស(តៃវ៉ាន់បច្ចុប្បន្ន) នៅប៉េស្កាដ័រ និងផ្ទាំងទម្លាក់គ្រាប់បែកលើហ្វូចូវ ។ ខាងជើងគោក បារាំងធ្វើប្រតិបត្តិការសឹកនៅសណ្តូរមេគង្គ ប្រយុទ្ធនឹងកងទ័ពទង់លឿង កងទ័ពទង់ខ្មៅ ដែលសុទ្ធតែជាកងទ័ពចិន (Les forces armées pavillons jaunes, pavillons noirs) ។ អាណានិគមបារាំងមកច្បាំងយកយួនពីចិន ។ ទាល់តែដល់ថ្ងៃ៩មិថុនា ១៨៨៥ ទើបបង្ខំឱ្យចិនចុះសន្ធិសញ្ញានៅទៀនស៊ិន ប្រទេសចិន ថែងថាចិនសុខចិត្តទទួលស្គាល់អាណាព្យាបាលបារាំងត្រួតត្រាលើអាណ្ណាម តុងកឹង(២០) ។ នៅក្នុងអនុស្សាវរណៈ មានចំណីមួយចារឡាស់ថា *"នឹងកំណត់ព្រំដែនឱ្យបានច្បាស់លាស់ រវាងអាណ្ណាមនិងមហាចក្រចិន"* ។ ការថែងពាក្យថា *"នឹងកំណត់ព្រំដែនឱ្យច្បាស់"* បានសេចក្តីថាព្រំដែននេះគ្មានទេពីមុនមក ។ ទស្សនៈព្រំដែនជាខ្មែរ ជាទស្សនៈថ្មីណាស់នៅសម័យនោះ ។

ការដែលយួនរួចផុតពីចំណុះចិននេះ បារាំងបានអនុញ្ញាតឱ្យយួនមានសិទ្ធិចាត់ចែងលើទឹកដីខ្លួនថ្មីតាមចិត្តផង ហើយចាត់ចែងលើជនជាតិដទៃជិតខាងផង ។ សូមរំលឹកថា មុនបារាំង

មកដល់ រាជធានីយួនគឺនៅហ្វេកុំមែននៅហាណូយទេ ។ ហ្វេជាទីក្រុងមួយដែលចិនសាងឡើងនៅសតវត្សរ៍ទី៣ ។ បារាំងត្រូវច្បាំងយ៉ាងខ្លាំង ដើម្បីបានចុះសន្ធិសញ្ញាឱ្យចិនទទួលស្គាល់ភាពជាអាណាព្យាបាលរបស់ខ្លួនលើយួនអាណ្ណាមតុងកឹង ក្នុងឆ្នាំ ១៨៨៥ ។ សន្ធិសញ្ញានេះត្រូវបានចុះហត្ថលេខា នៅធៀនស៊ិន ប្រទេសចិន ។ ជាការខុសគ្នាពីបញ្ហាខ្មែរដែលព្រះបាទ*នរោត្តម* ចុះហត្ថលេខាទទួលអាណាព្យាបាលបារាំងត្រួតត្រាខ្មែរ នៅក្រុងឧត្តុង្គ ។ បើខ្មែរចំណុះយួន បារាំងត្រូវទៅចុះហត្ថលេខាដាក់អាណាព្យាបាលលើខ្មែរជាមួយយួននៅក្រុងហ្វេ ដូចដែលបារាំងបានធ្វើនៅធៀនស៊ិនជាមួយចិនដូច្នេះដែរ ។ ហេតុនេះ មុនបារាំងមកដាក់អាណាព្យាបាល កម្ពុជាជាប្រទេសឯករាជ្យ គ្មានទ័ពបរទេស ឬទ័ពយួននៅលើដីខ្លួនទេ ។

### *៣- ប្រវត្តិយួនចំណាប់ខ្មែរ*

ក្នុងសម័យអាណានិគម វិធីដ៏ប្រសិទ្ធិភាពមួយក្នុងការធ្វើវៀតណាមូបនីយកម្មតំបន់កម្ពុជាក្រោម គឺប្រើតែភាសាបារាំងនិងយួនជាភាសាផ្លូវការ ក្នុងរដ្ឋបាលក្តី ក្នុងក្រសួងយុត្តិធម៌ក្តី ។ នៅកម្ពុជាក្រោម ពុំមានសាលា-វិទ្យាល័យបារាំង-ខ្មែរទេ មានតែសាលាបារាំង-យួន ។ មានតែបងប្អូនកម្ពុជាក្រោមទេ ទើបអាចសរសេរប្រវត្តិតស៊ូល្អិតល្អន់របស់ខ្មែរយើងនៅកម្ពុជាក្រោម ប្រឆាំងទប់ទល់នឹងនយោបាយយួនូបនីយកម្ម តាំងពីឆ្នាំ ១៦២០

ដែលជ័យជេដ្ឋាបានរៀបការជាមួយកូនស្រីយួនមក ។ ការតស៊ូរបស់វីរបុរសខ្មែរកម្ពុជាក្រោមយើង ត្រូវបានអ្នកប្រវត្តិសាស្ត្រធ្វើការស្រាវជ្រាវ ផ្តល់ពត៌មានដល់យើងក្រាស់ក្រៃលដែរ ។ ប៉ុន្តែអ្នកប្រវត្តិសាស្ត្រយួនម្នាក់ បានសរសេរច្បាស់ថា ស្តេចយួនអាណ្ណាមបានគ្រោងទុកយ៉ាងយូរមកហើយ អំពីការត្រៀមកូនស្រីឱ្យមករៀបការជាមួយជ័យជេដ្ឋាទី២ នៅឆ្នាំ ១៦២០ ។ ស្តេចសៃវ្វង បានអប់រំកូនស្រីតាំងពីនៅអាយុ ៨ ឆ្នាំ ឱ្យរៀបចំខ្លួនត្រៀមធ្វើជាមហេសីស្តេចខ្មែរ ។ ព្រះរាជពង្សាវតារខ្មែរបានសរសេរថា៖ *"ការបញ្ជូលមនុស្សយួនជាលើកទីមួយ មកក្នុងស្រុកខ្មែរ គឺក្នុងរជ្ជកាលជ័យជេដ្ឋាទី២ ។ ជ័យជេដ្ឋាទី២ បានទទួលជំនូនពីឪពុកក្មេកសៃវ្វង នៅថ្ងៃរៀបការ នូវនារីយួនចំនួន៥០០ បុរសយួនចំនួន៥០០ ដែលដង្ហែរក្សត្រីយយួនតាមសំពៅ ១៥ គ្រឿង ។ ខ្មែរបានហៅថាយួនចំណងដៃ ។ ចាប់ពីឆ្នាំ១៦២០ រហូតដល់ថ្ងៃស្លាប់ ស្តេចស្រីយួននេះតម្រូវនៅក្នុងវាំងខ្មែរ ឱ្យមានទីភ្នាក់ងារ អ្នកមុខអ្នកការ ជាជាតិយួនរបស់គេ និងអ្នកយាមបំរើគេ ៥០០ នាក់ ផ្លាស់វេនគ្នា មួយឆ្នាំពីរដង បញ្ជូនមកពីក្រុងហ្វេ ។ ទំនៀមទម្លាប់នេះបន្តរហូតដល់ពួកស្តេចយួនក្រោយៗទៀត គឺស្តេចយួនតែងតែបញ្ជូនយួនឱ្យមកជិតដិតនឹងវាំងខ្មែរ ។ ស្តេចឡៀងក៏បានប្រើវិធីនេះដែរ គឺបានឱ្យកងពលយួន៥០០នាក់ ជាចំណងដៃដង្ហែរអង្គម៉ីង មកស្រុកខ្មែរវិញ ក្រោយដែលអង្គម៉ីងបានភៀសខ្លួនទៅជ្រកស្រុកយួន នៅឆ្នាំ*

*១៦៥៧ ។ មុនសម័យអង្គឌួង ស្តេចយួនយ៉ាឡុង ក៏បានបញ្ជូនក្រុមយួន៥០០នាក់ ជាជំនូនដល់ព្រះបាទអង្គច័ន្ទ* (២២) ។

ហេតុនេះ បំណងជាយុទ្ធសាស្ត្រយួនច្បាស់លាស់ណាស់ ដែលចង់លេបយកដីខ្មែរបន្តិចម្តងៗ តាំងពីមុនឆ្នាំ ១៦២០ ។ សកម្មភាពទាំងឡាយរបស់យួន មិនដែលចាកឆ្ងាយពីទិសដៅយុទ្ធសាស្ត្រនេះទេ ទាំងមធ្យោបាយ ទាំងឧបាយកលផ្សេងៗ ។ យុទ្ធសាស្ត្រលេបខ្មែរបន្តិចម្តងៗ បានចាប់បដិសន្ធិឡើងតាមយួនចំណងដៃនេះឯង ។ យួនចំណងដៃបានចាប់ផ្តើមនៅឆ្នាំ១៦២០ ហើយត្រូវចប់នៅរជ្ជកាលព្រះបាទអង្គឌួង ១៨៤៨ ។ លុះផុតសម័យអង្គឌួង យួនចូលយកដីខ្មែរតាមរយៈអាណានិគម ។

តើយួនចំណងដៃនេះ អស់ប្រពៃណីវាហើយឬនៅ? យួនចំណងដៃនេះត្រូវបន្តធ្វើឡើងវិញ ដោយបក្សកុម្មុយនីស្តយួន តាំងពីឆ្នាំ ១៩៣០ មកដល់បច្ចុប្បន្ន ។

ដើម្បីទប់ទល់ចំណងដៃយួននេះ តើយើងជាខ្មែរ ចាំបាច់លើកទិសយុទ្ធសាស្ត្រ និងលើកផែនការហ្មត់ចត់ពិតប្រាកដឬទេ? សម័យ *អង្គឌួង* បានទុកមេរៀនមួយដ៏គួរឱ្យកត់សំគាល់ណាស់ ក្នុងប្រវត្តិសាស្ត្រយើង ។ អង្គឌួងមានទីប្រឹក្សាជាមហាសាស្ត្រាចារ្យម្នាក់ ឈ្មោះបណ្ឌិតចក្រី*ឌង* ។ បណ្ឌិតចក្រី*ឌង* ពិតជាអ្នកប្រាជ្ញខ្មែរម្នាក់នៅសម័យនោះ ដែលបានសរសេរចារព្រះរាជពង្សាវតារខ្មែរមុនគេ ដែលយើងស្គាល់ គឺនៅឆ្នាំ១៨១៨ ។ គឺបណ្ឌិតចក្រី*ឌង* នេះហើយ ដែលទូន្មាន*អង្គឌួង* ឱ្យចៀស

ផុតពីឧបាយកលយួន ។ អង្គឌួង បានគេចផុតពីវាសនាដែលអង្គឯម បានទទួលពីយួន ។ អង្គឯម បានជឿពាក្យសន្យាយួនថាឱ្យខ្លួនឡើងសោយរាជ្យ ក៏បានសុខចិត្តចេញចាកពីបាត់ដំបងមកភ្នំពេញ ។ លុះមកដល់ពោធិសាត់ មេទ័ពយួននៅទីនេះក៏បញ្ជូនអង្គឯមមកភ្នំពេញ ។ ឧបរាជអង្គឯម ឃើញមេទ័ពយួនទទួលខ្លួនយ៉ាងរាក់ទាក់នៅពោធិសាត់ ឥតយល់ការសម្ងាត់យួនក៏ស្មានថាយួនឱ្យកិត្តិយស យកទ័ពដង្ហែរមកភ្នំពេញ ។ មកដល់ភ្នំពេញ ប្រជារាស្ត្រនឹកស្មានថាឧបរាជមកជួយរំដោះខ្លួនពីយួន ក៏នាំគ្នាចេញមកទទួលអបអរតាមផ្លូវ ។ មេទ័ពយួនឈ្មោះ អុងតុងគុន ជំពាក់ទទួលឧបរាជអង្គឯមយ៉ាងរាក់ទាក់ឥតឱ្យមានមន្ទិលសង្ស័យអ្វីឡើយ ។ ការដែលប្រជារាស្ត្រទទួលអបអររាក់ទាក់ឧបរាជ នាំឱ្យអុងតុងគុន ឥតសប្បាយចិត្តទេ ។ លុះយប់ព្រលប់មកដល់ អុងតុងគុនក៏ចាប់អង្គឯមនិងរាជវង្សានុវង្សនិងបរិវារទាំងអស់ដាក់ទ្រុងដែក ហើយស្អែកឡើងក៏បញ្ជូនទៅគុកក្រុងហ្វេ(២៣) ។

ក្រោយពីធ្វើសង្គ្រាមយ៉ាងយូរ មិនព្រមចុះចាញ់យួន ពីឆ្នាំ ១៨៣៥ រហូតឆ្នាំ ១៨៤៨ អង្គឌួងបានកំចាត់ទ័ពយួនអស់ពីទឹកដីខ្មែរ ។ *អង្គឌួង* ឡើងសោយរាជ្យ ហើយតម្រូវឱ្យក្រុងហ្វេប្រគល់ព្រះខ័ន្ធរាជនិងមកុដរាជមករាំងខ្មែរវិញ ព្រមទាំងតម្រូវឱ្យយួនដោះលែងរាជវង្សានុវង្សនិងសេនាមន្ត្រី រាស្ត្រខ្មែរទាំងអស់ដែលយួនបានចាប់យកទៅដាក់គុកនៅក្រុងហ្វេ ។ ព្រះបាទអង្គ

ខ្លួង បានរៀបចំកសាងប្រទេសឡើងវិញលើគ្រប់ផ្នែក ផ្នែករដ្ឋបាល ផ្នែកយោធា ផ្នែកសេដ្ឋកិច្ច ដោយបោះត្រាក់ខ្លួង ។ អង្គខ្លួងរក្សាទីប្រឹក្សាជុំវិញខ្លួនដែលជាអ្នកចេះដឹងជ្រៅជ្រះ ។ អង្គខ្លួងយកចិត្តទុកដាក់លើប្រវត្តិសាស្ត្រ អក្សរសាស្ត្រ ។ នៅឆ្នាំ ១៨៥៨ អង្គខ្លួងបានបញ្ជាឱ្យមហាចក្រីកៃបលើកទ័ពទៅរំដោះតំបន់ទ្រាំងត្រើយត្បូងពីយួន ។ ព្រះបាទអង្គខ្លួងតែងសាងសង់ចេតិយជាច្រើននៅក្រុងឧត្តុង្គ លើភ្នំចិតរីស ឧទ្ទិសដល់អ្នកមានគុណចំពោះទឹកដីខ្មែរ ។ ព្រះបាទអង្គខ្លួងតែងធ្លាប់សង្កេតនយោបាយក្នុងនិងក្រៅប្រទេសរបស់ស្តេចសៀម រាមាទី២(១៨២៤-១៨៥១) និងរាមាទី៤ ហៅមង្គុត (១៨៥១_១៨៦៨) ។

សម័យ អង្គខ្លួង បានបញ្ចប់ប្រពៃណីយាយួនចំណាងដៃ ។ សម័យ អង្គខ្លួង បានការពារទឹកដីកម្ពុជាក្រោម ឱ្យនៅជារបស់ខ្មែររហូតដល់សម័យអាណានិគម ។ បើយើងពិនិត្យសំបុត្រព្រះបាទអង្គខ្លួង សរសេរទៅណាប៉ូឡេអុង យើងឃើញថា អង្គខ្លួងឥតបានសរសេរទៅសុំអាណាព្យាបាលពីបារាំងទេ ។ អង្គខ្លួងបានសរសេរទៅណាប៉ូឡេអុង ក្នុងទិសចងសម្ព័ន្ធភ្នា ដើម្បីការពារទឹកដីខ្មែរ ។ សូមអានសំបុត្រជាភាសាបារាំងក្នុងនិក្ខេបបទរបស់លោក ហ៊ូនីម (២៤) ។ សំបុត្រនេះនៅសល់ តែក្នុងឯកសារបារាំងជាភាសាបារាំង ។ សំបុត្រនេះបញ្ជាក់ថា អង្គខ្លួងបានទុកចិត្តលើណាប៉ូឡេអុង ។ តែអង្គខ្លួង បានបញ្ជាក់គោលការណ៍ការពារទឹកដីរបស់ខ្លួនច្បាស់ណាស់ ដោយសុំឱ្យបារាំង

គោរពដល់ផលប្រយោជន៍ខ្មែរ ។ ប៉ុន្តែ អង្គខ្លួនត្រូវសោយទិវង្គត់ទៅនៅឆ្នាំ ១៨៦០ ក្នុងក្ដីអាថ៌កំបាំងជាទីបំផុត ដោយឥតដឹងថាតើការទុកចិត្តលើបារាំង បាននាំឱ្យទឹកដីខ្មែរដែលខ្លួននិងវីរបុរសខ្មែរជាច្រើនបានយកជីវិតទៅការពារនេះ ត្រូវបាត់បង់យ៉ាងណាខ្លះ ?

### ៤- ការផ្លាស់ប្ដូរនយោបាយរបស់អាណានិគមចំពោះខ្មែរ

តើហេតុអ្វី បានជានយោបាយអាណានិគមបែរទៅជួយយួនជាងខ្មែរ? ពេលមកដល់កូស្សាំងស៊ីន តើអាណានិគមមានចិន្តាការយ៉ាងណាចំពោះខ្មែរ? ចំពោះយួនការវិវត្តន៍ដូចម្ដេចខ្លះ ? បើយើងសង្កេតតាមស្នាមប្រវត្តិសាស្ត្រខ្លះ យើងឃើញថាពេលដែលបារាំងទើបនឹងមកប៉ះទឹកដីកម្ពុជាមុនដំបូង គេហាក់មានការយកចិត្តទុកដាក់ចំពោះខ្មែរច្រើន មានអ្នកស្រឡាញ់ចូលចិត្តរាប់អានខ្មែរដូចជាអាដេម៉ាឡឹក្លែរ (Adhémard Leclerc) ដូចជាប៉ាវី (Pavy) និងមូរ៉ា (Moura) ជាដើម ។ ប៉ាវី បាននាំកូនខ្មែរទៅរៀន និងបង្កើតសាលាសំរាប់រៀនភាសាបារាំងហៅថា "មីស្យុងកម្ពុជា" ដែលក្លាយមកជា "សាលាកម្ពុជា" ។ សាលាកម្ពុជា នេះស្រាប់តែត្រូវប្ដូរឈ្មោះទៅជា "សាលាអាណានិគម" វិញនៅឆ្នាំ១៨៨៥ (២៤) ។

ហេតុអ្វីក៏នយោបាយអាណានិគមត្រូវប្ដូរចំពោះខ្មែរ បែរទៅរកយួននៅរវាងឆ្នាំ ១៨៨០ ? ទិសដៅអាណានិគមដែល

មកដល់ជ្រោយកូស្នាំងស៊ីនដំបូង គឺពុំមែនសំដៅស្រុកយួន ឬស្រុកខ្មែរព្រោកដទេ ។ ទិសដៅរបស់គេគឺសំដៅស្រុកចិន ដែលជាស្រុកមានធនធានធំ ។ ស្រុកចិនជាក្តីស្រម័យចង់បានរបស់បារាំងរាប់សតវត្សមកហើយ ។ នៅពេលដែលបារាំងចាប់ចូលទន្ទ្រានកាន់កាប់កូស្នាំងស៊ីន រួចហើយកាន់កាប់កម្ពុជានេះ បារាំងគេគិតថាដើម្បីឡើងចូលទៅរកស៊ីដល់ស្រុកចិនកណ្តាលបានលុះត្រាតែទៅតាម "ទន្លេមេគង្គ" ។ បើត្រូវឡើងតាមមេគង្គគេត្រូវតែសំរូលជាមួយខ្មែរ ។ ប៉ុន្តែបេសកកម្មពិសេសដែលនាំដោយឌូដាដឺឡាគ្រេ (Doudard De Lagrée) ដើម្បីស្រាវជ្រាវពីសភាពការណ៍ផ្លូវមេគង្គ ឆ្នាំ១៨៦៨ បាននាំឱ្យគេឃើញថា ផ្លូវមេគង្គនេះទៅមិនរួចទេ ។ គេឡើងពីសណ្តូរមេគង្គមកតាមកម្ពុជា ត្រូវកាត់តាមច្រកល្បាក់ទឹកធ្លាក់ខ្ពស់ៗច្រើនណាស់ដូចជានៅល្បាក់ខោនជាដើម ។ ហេតុនេះ ផ្លូវមេគង្គមិនអាចនាំទៅដល់កណ្តាលស្រុកចិនបានទេ ។ គេមិនអាចដឹកទំនិញតាមមេគង្គបានទេ ។ បេសកកម្ម ឌូដាដឺឡាគ្រេ នេះ បានកំណត់ថា គេត្រូវតែរកផ្លូវផ្សេង ថ្មីល្បិតតែឌូដាដឺឡាគ្រេ បានទៅដល់យូណានប្រទេសចិនមែន តែទាំងលំបាកណាស់ ។ ពេលទៅដល់យូណាន បារាំងបានឃើញថា ទំពអង់គ្លេសបានមកដល់ស្រុកចិនតាមប្រទេសភូមា ។ ប៉ុន្តែបារាំងក៏បានរកឃើញផ្លូវថ្មីដើម្បីទៅដល់ស្រុកចិន គឺ "ទន្លេក្រហម" នៅតុងកឹង (ហាណូយបច្ចុប្បន្ន) ។ ឌូដាដឺឡាគ្រេ ក៏ត្រូវស្លាប់នៅយូណានទៅ ។

ហេតុនេះ ដើម្បីទៅដល់ស្រុកចិន គេត្រូវតែកាន់កាប់តុងកឹងឱ្យបានជាចាំបាច់ ដើម្បីប្រើទន្លេក្រហមបាន ។ ដូច្នេះ ផលប្រយោជន៍បារាំងមានការផ្លាស់ប្ដូរ ត្រូវយកយួនមកប្រើការជាសំខាន់ ។ បារាំងត្រូវការយួនការពារតុងកឹងពីចិន ត្រូវការផ្ដាច់តុងកឹងពីចិនសិន ទើបយកទន្លេក្រហមឡើងទៅលើទៀតបាន ។ នេះហើយមូលហេតុដែលនាំឱ្យបារាំងជ្រើសរើសហាណូយដាក់ជារដ្ឋធានីនៃសហគមន៍ឥណ្ឌូចិន ។ ផលប្រយោជន៍បែបនេះហើយ ដែលនាំឱ្យបារាំងងាកចិត្តពីខ្មែរ ប្ដូរនយោបាយទន់ភ្លន់ពីមុនចំពោះខ្មែរ បែរខ្នងដាក់ខ្មែរ ទៅញញឹមដាក់យួន ។ នយោបាយនេះហើយ ដែលយើងឃើញនៅលើផលវិបាកគ្រប់ជំពូកមកលើខ្មែរ នាសម័យអាណានិគម ។ ផលវិបាកនេះបានឱ្យចំណេញទៅយួនរហូតដល់បច្ចុប្បន្ន ។

តើប្រវត្តិសាស្ត្រនៅតែវិលជាន់គន្លងចាស់ដដែលទៀតដែរឬទេ ? តើយើងត្រូវចាប់អារម្មណ៍ខ្លាំងដល់ករណីនេះដែរឬទេ អំពីពាក្យថា "*ចំនាស់ទាំងឡាយ គឺជាចំនាស់រវាងផលប្រយោជន៍ពុំមែនជាចំនាស់រវាងមនោសញ្ចេតនាស្រឡាញ់ស្អប់នោះទេ?*" តើចំនាស់រវាងផលប្រយោជន៍មហាអំណាចបស្ចិមប្រទេសនិងយើងបច្ចុប្បន្នដូចម្ដេចខ្លះ ? តើមហាអំណាចណាសុខចិត្តចំណាយមកជួយប្រជាជនមួយ ដែលគ្មានសមត្ថភាពធ្វើការរួបរួមគ្នាដើម្បីការពារទឹកដីខ្លួន មាតុភូមិខ្លួនឬទេ ?

# ៧

# ជាតិ ដើមកំណើត និងប្រវត្តិសាស្ត្រ

ការស្គាល់ ការចេះដឹងអំពីប្រវត្តិសាស្ត្រខ្លួន ជាការចាំបាច់ដើម្បីឈានទៅកសាងជាតិមួយឯករាជ្យបាន ឯកភាពបាន ក្នុងបូរណភាពដែនដីខ្លួន និងដើម្បីឈានទៅរកការកសាងប្រជាធិបតេយ្យ និងសេចក្តីរុងរឿងជូនប្រជាជនបាន ។

យើងតែងប្រើពាក្យថា *ជាតិ* ។ អត្ថន័យនៃពាក្យ "ជាតិ" ទើបតែត្រូវគេកំណត់ច្បាស់លាស់ នៅសតវត្សរ៍ទី២០នេះហើយទេ ។ មនោសញ្ចេតនា ជាតិ មានយូរហើយពិត ប៉ុន្តែគំនិតទស្សនៈ កំណត់ជាតិ ជាទស្សនៈថ្មី ។ នៅលើសកលលោក

បច្ចុប្បន្ន ពាក្យ *ជាតិ* អាចសង្ខេបបានដូចតទៅ៖ *ហៅថាជាតិមួយ គឺមនុស្សមួយក្រុមដែលមានគុណៈដូចគ្នា ចង់រស់នៅលើទឹកដីមួយមានព្រំដែនច្បាស់លាស់ មានដើមកំណើតដូចគ្នា មានប្រវត្តិសាស្ត្រ វប្បធម៌ប្រពៃណីមួយ ភាសានិយាយសរសេរមួយដូចគ្នា ក្រោមការចាត់តាំងជារចនាសម្ព័ន្ធមួយ សំរាប់រក្សាឯកភាពគ្នា ដើម្បីការពារបូរណភាពទឹកដីខ្លួន ព្រំដែនខ្លួនមិនឱ្យបរទេសឈ្លានពានបាន* ។ ហៅថា ជាតិ មួយបានលុះត្រាតែមនុស្សទាំងអស់ដែលនៅក្នុងជាតិនោះ មានចំណងប្រវត្តិសាស្ត្រ ចំណងវប្បធម៌ ចំណងភាសា ចំណងទឹកដីជាប់ជាមួយគ្នា ។ ហៅថាជាតិមួយបាន លុះត្រាតែអ្នករស់នៅក្នុងជាតិនោះសុខចិត្តគោរពលើកស្ទួយការពារសក្ការៈរបស់ជាតិខ្លួន ខ្ពស់ជាងអ្វីៗទាំងអស់ ។ សក្ការៈរបស់ជាតិគឺ ទឹកដី ប្រវត្តិសាស្ត្រ វប្បធម៌ ភាសា ។ បើបាត់អ្វីមួយក្នុងសក្ការៈទាំងនេះ គឺយើងបាត់ជាតិ ។ បើទឹកដីត្រូវគេឈ្លានពាន ការពារមិនបាន ក៏យើងបាត់ជាតិ ។ បើប្រវត្តិសាស្ត្រត្រូវគេបំបាត់ ក៏យើងការពារជាតិយើងមិនបាន ។ បាត់ប្រវត្តិសាស្ត្រគឺបាត់ព្រលឹងខ្លួន ។ រីឯវប្បធម៌ និងភាសាក៏ដូច្នេះដែរ ។ ហេតុនេះហើយបានជាអ្នកឈ្លានពាន ពេលយកទឹកដីបានហើយ តែងសរសេរប្រវត្តិសាស្ត្រថ្មីបំបាត់ប្រវត្តិពិតរហូតមិនឱ្យយើងរៀននិងប្រើភាសាយើងទៀត ។ សូមរំលឹកថា ទស្សនៈនៃពាក្យ ជាតិ ចេញមកអំពីមនុស្សដែលរស់នៅផ្តុំគ្នាក្នុងទីក្រុង ។ គឺរចនាសម្ព័ន្ធក្រុងនេះហើយដែលជាគ្រឹះនៃ

រចនាសម្ព័ន្ធជាតិ ។ រចនាសម្ព័ន្ធទីក្រុងអង្គរ គឺជាគ្រឹះនៃរចនាសម្ព័ន្ធមហាចក្រកម្ពុជា ជាគ្រឹះនៃអារ្យធម៌ខ្មែរ ។

យើងបានខិតខំសាកល្បងលើកយកបំណែកមួយដ៏តូច អំពីបញ្ហាព្រំដែនខ្មែរ-យួន មកជូនបងប្អូនពិចារណា ។ ប៉ុន្តែបញ្ហារបស់ជាតិយើងជាច្រើនណាស់ដែលនៅកប់ជ្រៅក្នុងប្រវត្តិសាស្ត្ររបស់ជាតិយើង។ តើកូនខ្មែរយើងមាននិស្ស័យអំពីប្រវត្តិសាស្ត្រខ្លួនឬទេ? កូឡែតបូន (Colette Beaune) អ្នកប្រវត្តិសាស្ត្របារាំងម្នាក់សរសេរក្នុងសៀវភៅឈ្មោះ"កំណើតនៃជាតិបារាំង" ថា៖ *កាលណាជាតិមួយមានការភ្ញាក់រលឹក ចាប់អារម្មណ៍អំពីជីវិតខ្លួនហើយ ជាតិនេះតែងតែស្វែងរកអតីតកាល ដើម្បីយកមកបំភ្លឺបច្ចុប្បន្នភាព* ។ គ្មានអ្វីអាចឆ្លុះបំភ្លឺជីវិតបច្ចុប្បន្នបានប្រសើរជាងប្រវត្តិសាស្ត្រទេ ។ បើយើងនិយាយតាមបែបម្យ៉ាងទៀត គឺអ្នកប្រវត្តិសាស្ត្រជាអ្នកបង្កើតជាតិ ជាអ្នកផ្តល់ខ្លឹមសារ ធ្វើឱ្យជាតិមានន័យ ។

យើងចាប់អារម្មណ៍ថា ខ្លួនយើងស្ថិតនៅក្នុងជាតិណាមួយលុះត្រាណាតែយើងស្គាល់ជាតិនោះច្បាស់ គឺស្គាល់រូបកាយចិត្តរបស់ជាតិ គឺស្គាល់ភូមិសាស្ត្រទឹកដី ដោយក្តីស្រឡាញ់ ដោយមោទនភាព តាមរយៈប្រវត្តិទាំងឡាយរបស់ជាតិ ។ គេសុខចិត្តបូជាអ្វីៗដើម្បីជាតិមាតុភូមិ លុះត្រាណាតែគេស្រឡាញ់ជាតិនោះ ដោយសេចក្តីស្នេហាមួយ លើសអ្វីៗទាំងអស់ គឺលើសពីជីវិតខ្លួនទៅទៀត ។

ប្រវត្តិរបស់កម្ពុជាយើងបានសរសេរដំបូងឡើង លើសិលាចារឹកនៃប្រាង្គប្រាសាទតូចធំ ផ្តិតស្នាមដានអារ្យធម៌ខ្មែរ ។ រីឯប្រវត្តិសាស្ត្រដែលសរសេរលើក្រដាស ភាគច្រើនលើសលប់តែងតែសរសេរដោយអ្នកនិពន្ធបរទេស ដែលយើងចាំបាច់ធ្វើការបកស្រាយដោយប្រុងប្រយ័ត្នបំផុត ។ នៅក្នុងសំណេរទាំងឡាយ យើងតែងប្រទះ "រឿងព្រេង" ដែលគេសរសេរបញ្ជាក់ពីដើមកំណើតកម្ពុជាយើង ។ ជាតិនីមួយៗហាក់ដូចជាមនុស្សមួយរូបដូច្នេះដែរ គឺតែងតែចង់រក "ឫស" គល់របស់ខ្លួន រកស្គាល់ពីអត្តសញ្ញាណរបស់ខ្លួន ព្រោះមនុស្សឥតអត្តសញ្ញាណគឺដូចជាមនុស្សគ្មានម៉ែគ្មានឪដូច្នេះដែរ។ កូឡែតបូន (Colette Beaune) (២៦) សរសេរថា៖ *ជាទូទៅគេនិយមជឿថា មនុស្សលោកយើងពុំមែនកើតមកដោយការធ្លាក់ផ្លែបន្តិចម្តងៗ ដោយវប្បធម៌និងពិសោធន៍របស់ខ្លួនទេ ។ គេនិយមជឿថា មនុស្សកើតមកពីស្ថាប័នអាទិទេព ដែលបង្កើតមកហើយគ្មានអ្វីប្រែប្រួលទេ* ។ លោកស្រី កូឡែតបូន ចង់បង្ហាញហេតុផលនៃការប្រើរឿងព្រេង សំរាប់ពន្យល់ឫសគល់នៃជាតិនីមួយៗ ក្នុងសំណេរផ្សេងៗរបស់អ្នកប្រវត្តិសាស្ត្រ ។ ដោយគេមិនអាចដឹងអំពីឫសគល់ ឫសកែវរបស់ជាតិនីមួយៗបាន អ្នកប្រវត្តិសាស្ត្រជាតិនីមួយៗលើសកលលោក តែងនិយមយករឿងព្រេងណាមួយមកចងក្រងជាប្រវត្តិដើមកំណើតរបស់ជាតិខ្លួន តាមទស្សនៈមួយលើកមោទនភាពដល់ជាតិខ្លួន ។ ពុំដែលមានអ្នកប្រវត្តិសាស្ត្រ

ជាតិណាមួយសរសេរថា ដើមកំណើតខ្លួនកើតមកពីមនុស្សអន់ថយទេ ។ គេសុទ្ធតែចុះមកពីពូជអ្នកខ្លាំងពូកែណាមួយជានិច្ច។

ឧទាហរណ៍ ពួករ៉ូម៉ាំងបានបង្កើតរឿងព្រេងពីប្រវត្តិសាស្ត្រឫសគល់ខ្លួនដូចម្ដេចខ្លះ? អ្នកកវីនិពន្ធដ៏ល្បីម្នាក់ឈ្មោះ វៀរហ្ស៊ីល (Virgile) បានសរសេររឿងកវីមួយ នៅឆ្នាំទី២៩ មុន គ.ស. ឈ្មោះរឿង*អេនេអ៊ីត* ។ អេនេអ៊ីត ជារឿងរបស់មហាចក្ររ៉ូម៉ាំង ដែលមានដើមកំណើតកើតឡើងដោយអ្នកចម្បាំងខ្លាំងពូកែម្នាក់មកពីក្រុង*ទ្រ័រ* ឈ្មោះ*អេនេ* ។ ក្រោយពីចាញ់សង្គ្រាមក្រិកនៅក្រុងទ្រ័រហើយ មេទ័ពអេនេ បានរត់មកកសាងស្រុកមួយថ្មីគឺស្រុករ៉ូម៉ាំង ។ អេនេគឺជាក្សត្រាមួយអង្គ ជាបុត្រារបស់ទេពអប្សរ*អាហ្វ្រូឌីត* និង*អង់ស៊ីស* (Aphrodite et Anchise)។ ក្សត្រាអេនេបានច្បាំងយ៉ាងក្លាហានអស្ចារ្យណាស់ តទល់នឹងកងពលក្រិកនៅក្រុងទ្រ័រ ក្នុងរឿងអ៊ីលីយ៉ាតរបស់អូមែរ ឆ្នាំ១៣០០ មុនគ.ស. ។ ពេលដែលក្រុងទ្រ័រត្រូវក្រិកព័ទ្ធបានហើយ អេនេក៏បីឪពុកខ្លួនឈ្មោះអង់ស៊ីសរត់ចេញពីក្រុងទ្រ័រ ។ ការរៀបរាប់ដំណើរភៀសខ្លួនរបស់អេនេ គ្មានខុសអ្វីពីអូឌីសេ (២៧) របស់អូមែរទេ ។ អេនេបានរត់មកដល់ អ៊ីតាលី នៅវាលឡាស្យូម ។ អេនេក៏បានជួបក្សត្រីយមួយអង្គឈ្មោះ ឡាវីណា ជាកូនរបស់ស្ដេចឡាស្យូម ។ ក្រោយពីរៀបការជាមួយឡាវីណាហើយ អេនេក៏ឡើងសោយរាជ្យ កសាងសង់វាលឡាស្យូមដែលក្លាយមកជាក្រុងរ៉ូមបច្ចុប្បន្ននេះ ។

ប្រវត្តិដើមកំណើតជាតិវៀតណាមរបស់វៀតមិញនេះ បាននាំឱ្យជាតិវៀតណាមមានមោទនភាពលើជាតិខ្លួនណាស់ ថាខ្លួនមានប្រវត្តិយូរលង់ផង ថាខ្លួនកើតមកពីពូជអ្នកច្បាំងខ្លាំងពូកែម្នាក់មកពីក្រុងទ្រ័រ តាំងពី១៣០០ឆ្នាំ មុនគ.ស. ។ នេះជាប្រវត្តិដើមកំណើតវៀតណាម ដែលសរសេរដោយជាតិវៀតណាមខ្លួនគេ ។ ប៉ុន្តែរឿងព្រេងដែលនិយាយពីដើមកំណើតខ្មែរវិញ ជារឿងដែលនិពន្ធដោយអ្នកប្រវត្តិសាស្ត្របារាំងជាមូលដ្ឋាន ។ រឿងព្រះបាទហ៊ុនទៀន ជាជាតិក្លិង្គមកជួបព្រះនាងលីវយីលើកោះគោកធ្លកកសាងទឹកដីកម្ពុជានេះ ពុំមានអ្វីខុសគ្នាពីរឿងអេនេ និងព្រះនាងឡាវីណា នៅឡាលាស្យូម ស្រុកដើមនៃក្រុងរ៉ូមនោះទេ ។ ការលើកឈ្មោះហ៊ុនទៀនជាដើមកំណើតខ្មែរនេះ វាត្រូវតាមចំណង់ទស្សនៈអ្នកប្រវត្តិសាស្ត្រជាច្រើន ដែលគេនិយមចាត់ទុកថាខ្មែរជាជាតិទន់ខ្សោយ ពុំអាចសាងសង់អង្គរល្អប្រណីតបែបនេះបានទេ ទាល់តែឥណ្ឌាមកសង់ឱ្យទើបធ្វើបាន ។ ចុះហេតុអ្វីក៏ឥណ្ឌាគេមិនសង់អង្គរនៅស្រុកគេ បែរជាមកសង់អង្គរនៅស្រុកខ្មែរទៅវិញ? ការមានឥទ្ធិពលទៅវិញទៅមកជាការធម្មតា គឺជាការឆ្លាក់ឆ្លងនៃវប្បធម៌ជាតិផ្សេងមកលើជាតិនីមួយៗ ។

អឺរ៉ុបមានរបៀបក្នុងការស្រាវជ្រាវរកដើមកំណើត ព្រោះគេចេះរក្សាឯកសារសរសេរបាន ។ គេអាចរកឃើញឡើងវិញបន្តិចម្តងៗថា រឿងព្រេងទាំងឡាយ សរសេរឡើងនៅឆ្នាំណាពេលណាបាន ។ ឧទាហរណ៍ អំពីរឿងព្រេងដើមកំណើត

បារាំង ក៏ប្រហាក់ប្រហែលនិងរឿងខាងលើនេះដែរ ដែលយើងសូមដកស្រង់ពីសៀវភៅ អ្នកស្រីកូឡែតបូន ដដែល គឺរឿង "ហ្វ្រង់ស្យុង" ។ រឿងហ្វ្រង់ស្យុងនេះមានពីររយៈ ។ នៅក្នុងឆ្នាំ ៦៦០ អ្នកនិពន្ធបារាំងម្នាក់ឈ្មោះហ្វ្រេហ្គេដែរ (Frégédaire) បានសរសេរបញ្ចូលហ្វ្រង់ស្យុង មកក្នុងប្រវត្តិកំណើតបារាំងក្នុងសៀវភៅឈ្មោះប្រវត្តិបារាំង (Histoiria Francorum) ។ ហ្វ្រង់ស្យុង ជាកូនប្រុសរបស់ហ្វ្រីហ្គា (Frigar) ប្អូនប្រុសរបស់អេនេ ។ ហ្វ្រង់ស្យុងបានសង់មហាចក្រមួយនៅចន្លោះទន្លេរ៉ាំងនិងទន្លេដានូប ដែលមានទំហំដីជាអាល្លឺម៉ាញ បារាំង អូទ្រីស្ស បច្ចុប្បន្នបញ្ចូលគ្នា ។ ប៉ុន្តែ ហ្វ្រង់ស្យុងជាស្តេចមានជាប់សាច់ឈាមជាមួយអង់គ្លេស និងទួរគី ដែលជាសត្រូវខ្លួន ។ ហេតុនេះ រឿងព្រេងបន្តមួយក៏មកបន្ថែមថា ហ្វ្រង់ស្យុងបានកំទេចពួកទួរគុស និងព្រួស (ទួរគុសមកពីពាក្យទួរគី, ព្រួស មកពីពាក្យអង់គ្លេស) ។ រីឯរឿងព្រេងឱ្យដើមកំណើតបារាំងសរសេរនៅដើមគ.ស. ថាមានកូនក្មួយមួយរបស់ហ្វ្រង់ស្យុង ឈ្មោះម៉ាកូបៀរ បានមកតាំងទីនៅលើទឹកដីបារាំងបច្ចុប្បន្ន រៀបការជាមួយក្សត្រីយម្នាក់ឈ្មោះ ហ្វ្រង់សឺ ។ ម៉ាកូបៀរ ក៏ឱ្យឈ្មោះទឹកដីនេះថា ហ្វ្រង់សឺ ។ ម៉ាកូបៀរ និងនាងហ្វ្រង់សឺ បានកូនប្រុសមួយឈ្មោះហ្គាលុស (Gallus) ដែលក្លាយមកជាជនជាតិហ្គោល (Gaule) ។ បារាំងក៏កំណត់ថា ខ្លួនជាជនជាតិហ្គូឡូវ៉ា (Gaulois) តាំងពីពេលនោះមក ។

តើរឿងព្រះបាទ កោរិនញ៉ាហ៊ុនទៀន និងព្រះនាងលីវយី ខុសគ្នាពីរឿងហ្វូនស្យុង-ហ្គាលុសនេះឬ? ក្នុងបញ្ហានេះលោកស្រី *ត្រឹងងា* (២៨) បានសរសេរនៅក្នុងសៀវភៅមួយឈ្មោះ "ដើមកំណើតជាតិខ្មែរ" ឆ្នាំ១៩៧៣ថា *អ្នកសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រជនជាតិបរទេសខ្លះ ច្រើនតែនិយាយទាញភ្ជាប់ជាតិខ្មែរទៅនឹងជាតិណាមួយ ដែលគេយល់ថាមានអារ្យធម៌ខ្ពង់ខ្ពស់ជាងខ្មែរ* ។ ប៉ុន្តែលោកស្រី ត្រឹងងា បានឱ្យយោបល់ថា *តាមការស្រាវជ្រាវចុងក្រោយរបស់លោកហ្វ្រូលីយេ គេទទួលស្គាល់ច្បាស់ថា ជាតិខ្មែរជាជាតិមួយស្ថិតនៅក្នុងចង្កោមមន-ខ្មែរដែលកកើតឡើងនៅភូមិភាគអាគ្នេយ៍នេះ តាំងពីយូរលង់ណាស់មកហើយ* ។ លោកស្រីបញ្ជាក់ទៀតថា *ទោះជាយ៉ាងណាក៏ដោយក៏លុះត្រាតែមាននាងនាគជាខ្មែរនៅស្រុកខ្មែរតាំងពីដើមកំណើតមកដែរ* ។

បច្ចុប្បន្ននេះ អ្នកប្រវត្តិសាស្ត្រហ្នឹងចចំបានបោះបង់ចោលរឿងព្រេងទាំងឡាយ ចាប់យកផ្ទាំងសិលាចារឹកដែលគេជីកកកាយឃើញក្នុងដី មកធ្វើជាឯកសារប្រវត្តិសាស្ត្រ ។ បន្តិចម្តងៗ ឯកសារប្រវត្តិសាស្ត្រលែងឈរលើរឿងព្រេងដើម្បីពន្យល់ជាតិនិមួយៗអំពីដើមកំណើតរបស់ខ្លួនទៀតហើយ ។ ទោះជាថាខ្មែរមានឈាមក្លិង្គឬមានឈាមចិនលាយឡំគ្នាយ៉ាងណា ក៏គេមិនអាចជឿថា ក្លិង្គមកសង់សំណង់អារ៉ាយធម៌អង្គរជំនួសដូនតាយើង ទុកឱ្យយើងដែរ ។ លោកប៊ែរណាហ្វីលីពហ្វ្រូលីយេ

(Bernard Phillipe Groslier) និងអ្នកប្រវត្តិសាស្ត្រដើម (Préhistoriens) នៅសារៈមន្ទីរ គីមេ (Musée Guimet Paris-Lyon) និងនៅល្បុង បានកំណត់ថា អារ៉ីយធម៌ខ្មែរ មានកំណើតយ៉ាងតិចមួយពាន់ពីររយឆ្នាំមុនគ.ស. គឺអារ៉ីយធម៌ស៊ីវិតនៅសំរោងសែននិងនៅម្លូព្រៃ ។ លោកក្រូលីយេជាអ្នកស្រាវជ្រាវដ៏កម្រម្នាក់ដែលបានសិក្សាច្បាស់អំពីប្រព័ន្ធប្រើទឹកនៅបារាយអង្គរ ដោយលោកបានពន្យល់ថា នៅក្រោមរជ្ជកាលជ័យវរ្ម័នទី៧ ការប្រើប្រព័ន្ធទឹកនេះ បានឱ្យផលផល់កំពស់អតិបរមាយ៉ាងខ្ពស់បំផុតហើយ ។ គេមិនអាចទាញយកផលកសិកម្មឱ្យបានលើសពីកំរិតនេះទៀតទេ ។ ផលកសិកម្មត្រូវតែចុះថយ ព្រោះទឹកដីធម្មជាតិពុំអាចផ្តល់លើសនេះបានទៀតទេ មានតែរេចរិលចុះថយ ។ បើផលកសិកម្មចុះថយហើយ កម្លាំងប្រជារាស្ត្រក៏ត្រូវតែចុះថយ ចំនួនប្រជាជនក៏ចុះថយដែរ ។ លោក *គួន ឈឿន* បានឃើញច្បាស់សារៈសំខាន់នៃចំនួនប្រជាជន ក្នុងជាតិនិមួយៗ(២៥) ។

រឿងព្រេងដែលយើងចាំបាច់ប្រុងប្រយ័ត្នក្នុងការបកស្រាយប្រវត្តិសាស្ត្រមានច្រើន ហើយសុទ្ធតែសរសេរដោយអ្នកនិពន្ធបរទេស ។ ដោយសារតែគេសរសេរយូរមកហើយ អ្នកខ្លះក៏យកមកធ្វើជាគោលកំណើតពិត ។ រឿងស្តេចគង្វា មកកាត់កស្តេចខ្មែរនៅសតវត្សរ៍ទី៨ ក៏ជារឿងមួយគួរឱ្យពិនិត្យឡើងវិញ។

រឿងនេះជារឿងចេញពីប្រភពអារ៉ាប ។ ហេតុអ្វីបានជាចេញពីរឿងអារ៉ាប? ព្រោះរឿងនេះនិយាយថា ស៊ុឡាំងត្រា កាត់កស្តេចខ្មែរហើយក៏តម្រូវឱ្យស្តេចខ្មែរបង្អោនកាយ គោរពអ្នកមានបុណ្យ ដែលនៅចម្ងាយ១ពាន់គ.ម. ដោយបែរមុខទៅទិសអ្នកមានបុណ្យរាល់ថ្ងៃ ។ ការលំអោនកាយគោរពបែរមុខទៅទិសអ្នកមានបុណ្យនេះពុំមែនជាប្រពៃណីយខ្មែរទេ គឺជាប្រពៃណីយអារ៉ាប ។ សូមរំលឹកថា មហាចក្រភពសីឡាំងត្រា មានដើមកំណើតចេញពីខ្មែរ ។ គឺនៅក្រោមរាជសីឡាំងត្រានេះហើយដែលបានសង់ចេតិយដ៏សម្បើមនៅបូរ៉ូប៊ូឌួរនាសតវត្សរ៍ទី៩ ។ គឺជាសំណង់តែមួយគត់ដែលចាស់ជាងគេ មានចេតិយយ៉ាងច្រើនក្នុងទំហំដីមួយរយម៉ែត្របួនជ្រុងនៅឥណ្ឌូណេស៊ី ។ ការទាក់ទិនរវាងកម្ពុជា,ម៉ាឡេស៊ីា និង ស៊ូម៉ាត្រា ជ្វា ពីសតវត្សរ៍ទី៤ ដល់ទី១២ ស្ថិតនៅជាអាថ៌កំបាំងមួយដែលគេស្គាល់មិនប្រាកដនៅឡើយទេ ។

### ***ទ្រឹស្តីខាងសិលាចារិកលើដើមកំណើតខ្មែរ***

១. ខាងសិលាចារិកជាឯកសារលើប្រវត្តិដើមកំណើតខ្មែរ ដែលកត់ត្រាថាខ្មែរជាជាតិមួយមានប្រាជ្ញា មានស្នាដៃចាស់យូរលង់មកហើយ នៅមានច្រើនទៀត ។ ការស្រាវជ្រាវក្នុងដីពុំទាន់បានធ្វើហ្មត់ចត់នៅកម្ពុជាទេ ។ ការរកឃើញវត្ថុប្រើប្រាស់របស់មនុស្សនៅសម័យមុនប្រវត្តិសាស្ត្រ មានភស្តុតាងដូចជាថ្ម

ថ្មិត (Pierres taillées) អាយុប៊ីរយពាន់ឆ្នាំ ត្រូវរកឃើញនៅស្រែស្បូវខេត្តក្រចេះត្រើយខាងកើតទន្លេមេគង្គ នៅកំឡុងឆ្នាំ ១៩៦០-៦៣ ។ គេរកឃើញថ្មសំលៀង (Néolitique) និងក្អមឆ្នាំងអាយុ៨ពាន់ឆ្នាំ ។ គេរកឃើញសិរិតឆ្មាក់ អាយុបីពាន់ពីររយឆ្នាំ។ លោកព្រូលីយេបានរកឃើញក្រុងមូល (Cité ronde) ចំនួនរាប់រយកន្លែង ចាប់ពីខាងលិចទន្លេមេគង្គឡើងទៅដល់វៀងវៃ ។ អរិយធម៌ក្រុងមូលនេះ មានន័យថាមានមនុស្សរស់នៅលើដីខ្មែរ សង់ផ្ទះជាប់ៗគ្នាជារង្វង់មូល តាំងពីយូរលង់ណាស់មកហើយ ។ ការស្រាវជ្រាវរកឫសគល់នៃដើមកំណើតខ្មែរដែលមានតាំងពីសម័យមុនប្រវត្តិសាស្ត្រនេះធ្វើឡើងនៅក្រោយឯករាជឆ្នាំ១៩៥៤ គឺក្នុងរវាងឆ្នាំ ១៩៦០ ឮយ ។ មុនឯករាជ ទីស្នាក់ការសាលាបារាំងខាងបូព៌ាប្រទេស ស្ថិតនៅហាណូយ ។ ម្ល៉ោះហើយគេនិយមស្រាវជ្រាវតែក្នុងតំបន់តុងកឹង ។ អារ៉ីយធម៌សិរិតទីមួយដែលគេរកឃើញ គឺនៅដុងសឺនដំបន់តុងកឹង ។ សិរិតដុងសឺនមានអាយុ៥រយឆ្នាំមុនគ.ស. ។ ប៉ុន្តែការរកឃើញអ្វីៗក្រោយមកទៀត ទោះជាមានអាយុច្រើនជាងសិរិតដុងសឺនយ៉ាងណាក៏ដោយ ក៏គេនៅតែហៅថាអារ៉ីយធម៌ដុងសឺន ។ យួនតែងអួតអាងណាស់ថា គេជាជនជាតិអារ៉ីយធម៌ដុងសឺន ជាជនជាតិចាស់ជាងគេនៅអាស៊ីអាគ្នេយ៍ ។ ប៉ុន្តែជាការចម្លែក អារ៉ីយធម៌សិរិតរកឃើញនៅម្លូព្រៃ នៅសំរោងសែន ដែលមានអាយុមួយពាន់ពីររយឆ្នាំមុនគ.ស. ក៏នៅតែ

ត្រូវអ្នកឯកទេសបារាំងដាក់ឈ្មោះថាជាអារីយធម៌ដុងសឺនដែរ ។ លោកហ្គូលីយេបានវែកញែកបញ្ជាក់ក្នុងឯកសាររបស់លោកថា *នៅកម្ពុជា មានការបន្តតគ្នាពីអារីយធម៌សំរោងសែន មកដល់អារីយធម៌អង្គរ* ។ សូមកត់សំគាល់ថា ការស្រាវជ្រាវខាងវត្ថុបូរាណនៅកម្ពុជាមកដល់បច្ចុប្បន្នច្រើនតែរិះរកតាមប្រាសាទដែលសល់នៅលើដីតែប៉ុណ្ណោះ ។ ការជីកកកាយពុំទាន់មានច្រើនទេ តែជាសំណាងម្យ៉ាងទៀតថាវត្ថុបូរាណទាំងនេះ នឹងមិនត្រូវគេលួចប្លន់ ។ នៅឆ្នាំ១៩៩៤ ការជីកដោយចៃដន្យនៅប្រាំមួយគ.ម.ពីភ្នំពេញ បានប្រទះវត្ថុបូរាណរាប់ពាន់គ្រឿង ដូចជាក្អមឆ្នាំងចាន ដែលខ្លះមានទំហំ៤០-៥០ស.ម.។ វត្ថុបូរាណទាំងនេះមានអាយុពីរពាន់ឆ្នាំ គឺជាអារីយធម៌ជំនាន់អុកអែវ ។ មុននឹងស្លាប់ទៅ លោកហ្គូលីយេ បានសរសេរឯកសារបណ្តាំមួយ ទិទានយ៉ាងតឹងរឹងលើការងាររបស់សាលាបារាំងខាងបូព៌ាប្រទេស(៣០) ។ នៅក្នុងឯកសារនេះ លោកបានចង្អុលប្រាប់កន្លែងសំខាន់ៗដែលត្រូវធ្វើការស្រាវជ្រាវរកវត្ថុបូរាណក្នុងដីនៅកម្ពុជានាអនាគត ។

២. បរិយាយអំពីអារីយធម៌សម័យប្រវត្តិសាស្ត្រវិញ

(Epoque historique) ភស្តុតាងដ៏ធំមួយនៃអារីយធម៌មនុស្សលោកដែលគេរកឃើញនៅកម្ពុជាគឺ ***សញ្ញាលេខសូន្យ*** ។ សញ្ញាសូន្យដ៏ចាស់ជាងគេនៅលើសកលលោក ត្រូវគេរកឃើញនៅកម្ពុជា

និងនៅ ស៊ូម៉ាត្រា ឆ្នាំ ៦០៥ នៃមហាសករាជ ដែលគេហៅថាសករាជ សាកា (៣១_៣២_៣៣) ។ សញ្ញាលេខសូន្យនៅកម្ពុជាយើង បានចារនៅលើសិលាចារឹកខែត្រព្រាំងព្រៃស្រុកសំបូរ ក្នុងកំណត់កត់ឆ្នាំ *៦០៥* មហាសករាជ ត្រូវនឹងឆ្នាំ ៦៨៣ នៃគ.ស. ។ សញ្ញាសូន្យនៅក្នុងចំនួន *៦០៥* នេះជាភស្តុតាងនៅកម្ពុជា ។ សញ្ញាសូន្យមានសារៈសំខាន់ណាស់ក្នុងគណិតសាស្ត្រមនុស្សលោក សំរាប់សរសេរចំនួនទសភាពដោយដំរៀបលេខបន្ទប់ ។ ការប្រើចំនួនទសភាពរៀបលេខបន្ទប់បានបង្កើតឡើងមុនគេនៅប្រទេសចិន តាំងពីសតវត្សរ៍ទី១៤មុនគ.ស. ។ ប៉ុន្តែចិនមិនបានបង្កើតសូន្យទេ គេទុកចន្លោះទទេមួយចោល ។ សូន្យដែលសរសេរមុនគេ គឺសូន្យនៅក្នុង៦០៥មហាសករាជនេះហើយ ។ ការរកឃើញសូន្យក្នុងជំនាន់ដូចគ្នានៅកោះស៊ូម៉ាត្រា ពុំមានអ្វីជាការចម្លែកទេ ព្រោះស្តេចនៅស៊ូម៉ាត្រា សម័យនេះវង្សកាលសីឡាំងព្រោ ជាពូជពង្សក្សត្រខ្មែរមួយអង្គដែលចេញពីកម្ពុជាទៅសោយរាជ្យនៅទីនោះ ។

៣- អំពីសិល្បៈសំរិតវិញ នៅអាស៊ីអាគ្នេយ៍ ខ្មែរជាអ្នកមានសិល្បៈចេះចាក់ពុម្ពរូបសំរិត ចាស់ជាងគេ ចេះសង់សំរិតទំហំធំជាងមួយម៉ែត្រ ។ យើងអាចប្រៀបធៀបទៅនឹងបច្ចេកទេសសំរិតស្រុកចិន ស្រុកឥណ្ឌាបាន(៣៤) ។

៤- ទំព័រអក្សរ៖ នៅអាស៊ីអគ្នេយ៍យើង ខ្មែរជាជាតិតែមួយគត់ដែលបានបង្កើតតួរអក្សររបស់ខ្លួន ហើយប្រើប្រាស់ជាប់រហូត ឥតដែលដាច់និងឥតមានផ្លាស់ប្ដូរច្រើន ។ អក្សរខ្មែរមួយអង្គៗមានរូបរាងរចនាទៅដោយសមប្បមាណ(Symétrie) និងមានក្បាច់សង្វាក្នុងការគូសខ្សែនីមួយៗដែលគេអាចសន្និដ្ឋានបាននូវថ្វីដៃសិល្បៈដ៏ឆើតក្នុងការចារអក្សររបស់ខ្លួន ។ យើងសូមលើកយកពាក្យរបស់លោក យេមហ្វេវ្រីយេ (James G. Février) សរសេរថា៖ Les premiers textes épigraphiques montrent une telle symétrie, une telle élégance dans la tracée des caractères, qu'on doit admettre qu'ils ont bénéficié d'une longue tradition scriptuaire. (៣៥) ។

ខ្មែរបានទាញចេញពីតួដើមអក្សរឥណ្ឌាមកប្រើប្រាស់ដោយបង្កើតតួថ្មី របៀបប្រើថ្មី មានលក្ខណៈពិសេសរបស់ខ្លួន ខុសពីឥណ្ឌាដើម ។ ការបង្កើតតួអក្សររបស់ខ្លួននេះ ចាត់ទុកថាជាស្នាដៃមួយធំណាស់របស់ខ្មែរ ។ ការប្រើសរសេរអក្សរ ខ្មែរនៅមានការលំបាកមែន តែគេពុំអាចបង្កើតក្បួនណាឱ្យបានឆើតជាងនេះទេ ។ ការលំបាកនៅក្នុងអក្សរខ្មែរ ជាមូលហេតុមួយនាំឱ្យពិបាកធ្វើម៉ាស៊ីនយកម្ម ។

អក្សរខ្មែរជាស្នាដៃមួយសំខាន់ណាស់ ដែលដូនតាយើងបានបង្កើតឡើងនៅដើមគ្រិស្តសករាជ ទុកកេរ្តិ៍បន្តឥតដាច់ដល់

យើងសព្វថ្ងៃដោយឥតសាបរលាប ។ មើលងាយអក្សរខ្លួន គឺមិនស្គាល់ថ្លៃដូនតាខ្លួន មិនស្គាល់ថ្លៃជាតិខ្លួន ។ សាស្ត្រាចារ្យឥណ្ឌូណេស៊ីម្នាក់នៅកោះបាលី បានប្រាប់ច្បាស់ថា នៅស្រុកសិង្ហា (Singa) ខាងជើងកោះបាលី មានតម្កល់គម្ពីរមួយសរសេរអំពីនគរខ្មែរ ។ គម្ពីរនេះសរសេរថា សាសនាព្រាហ្មគឺព្រហ្មញ្ញសាសនានៅកោះបាលី បាននាំយកមកពីនគរខ្មែរនៅសតវត្សរ៍ទី២នៃគ.ស. ។ គម្ពីរបានសរសេរថា នៅតំបន់អង្គរនគរខ្មែរ គឺជារម្មណីយដ្ឋានសំខាន់ណាស់ ដែលផ្គុំដោយប្រាសាទដ៏ស្កឹមស្កៃជាច្រើនលើសលប់ ពុំដែលមានក្នុងលោក ។ ទោះជានៅតំបន់ណាផ្សេងទៀតនៃអាស៊ី ក៏គេមិនដែលប្រទះតំបន់ណាមួយដែលមានផ្គុំប្រាសាទយ៉ាងច្រើនដូច្នេះដែរ ។ ទោះជានៅស្រុកក្លិង្គក្តី ស្រុកចិនក្តី ក៏គេមិនដែលប្រទះតំបន់ណាដែលមានសំណង់ប្រាសាទសិលាធំៗនិងចំនួនច្រើនបែបនេះដែរ ។

**៥- និស្ស័យប្រវត្តិសាស្ត្រខ្មែរ៖** ក្រោយសម័យអង្គរ តើខ្មែរយើងនៅមាននិស្ស័យប្រវត្តិសាស្ត្រឬទេ? យើងឆ្លើយថាមានជាក់ស្តែង គឺការចងចាំចារឈ្មោះស្តេចអ្នកសង់អង្គរវត្ត រាប់រយឆ្នាំជាបន្តឥតដាច់ ។ បើគេធ្វើការសិក្សាលើសិលាចារឹកក្រោយការចាកចេញពីអង្គរមក លោក*ពិនសុក* (៣៦) បានសរសេរថា៖ ***គេបានសង្កេតឃើញច្បាស់ថា រាប់រយឆ្នាំក្រោយមរណៈ***

*ភាគរបស់ស្ដេច ខ្មែរនៅតែលើកសរសើរតាមថ្វាយព្រះនាមដល់ព្រះរាជាដែលបានសាងសង់អង្គរវត្តនេះដដែលទៀត ។ ព្រះនាមនៃព្រះរាជាត្រូវបានស្ដេចបន្ទាប់ ឧទ្ទិសថ្វាយព្រះនាមថា មហាវិស្ណុលោក ដែលជាព្រះសុរិយាវង្សទី២ ។ គេសំគាល់បានថាការដឹងគុណនេះ ហាក់ហួសពីការចាំរបស់មនុស្ស ។*

យើងសូមកត់សំគាល់បន្ថែមថា ខ្មែរយើងតែងចាំក្នុងរឿងព្រេងអំពីឈ្មោះស្ដេចដែលបានសង់អង្គរវត្តហៅថា ព្រះពិស្ណុការ ដែលចេញមកពីមហាវិស្ណុការ ឬមហាពិស្ណុការ ។ រឿងព្រះពិស្ណុការ គឺជារឿងព្រេងដំណាលលើកដំកើងលំអសំរស់អង្គរវត្ត ។

**៦- អំពីព្រះរាជពង្សាវតារខ្មែរ៖** ដូចយើងបានរៀបរាប់ពីខាងដើម ព្រះរាជពង្សាវតារខ្មែរ ដែលចាស់ជាងគេដែលគេរកឃើញគឺ ព្រះរាជពង្សាវតារខ្មែរសរសេរនៅឆ្នាំ១៨១៨ ដោយបណ្ឌិតចក្រី*នង* គ្រូបាធ្យាយដ៏ចំណានម្នាក់របស់អង្គឌួង ។ ព្រះរាជពង្សាវតារទី២ ដែលពេញលេញជាងគេ ហើយដែលអ្នកប្រវត្តិសាស្ត្របារាំងតែងប្រើប្រាស់ បានសរសេរនៅឆ្នាំ ១៩២៩ តាមព្រះរាជពង្សាវតារទីមួយ ហើយសំរួលបំពេញសារឡើងវិញ ដើម្បីផ្សាយនៅឆ្នាំ ១៩៣៤ ។ គឺជាព្រះរាជពង្សាវតាររបស់សម្ដេច*ចៅវាំងជួន* ។ ប៉ុន្តែ ព្រះរាជពង្សាវតារទាំងនេះពុំដែលបោះផ្សាយជាសាធារណៈទេ ទោះជានៅសម័យរដ្ឋការអាណានិគមក្ដី ឬ នៅសម័យរដ្ឋការខ្មែរឯករាជក្ដី ។ ជាសំណាង

*ភាពរបស់ស្តេច ខ្មែរនៅតែរំលឹកសរសើរតាមថ្វាយព្រះនាមដល់ព្រះរាជាដែលបានសាងសង់អង្គរវត្តផងដែលភ្លេច ។ ព្រះនាមនៃព្រះរាជាត្រូវបានស្តេចបន្តរាជ ឧទ្ទិសថ្វាយព្រះនាមថា មហាវិស្ណុលោក ដែលជាព្រះសុរិយាវរ្ម័នទី២ ។ គេសំគាល់បានថាការដឹងគុណនេះ ហាក់ហួសពីការចាំរបស់មនុស្ស ។*

យើងសូមកត់សំគាល់បន្ថែមថា ខ្មែរយើងតែងចាំក្នុងរឿងព្រេងអំពីឈ្មោះស្តេចដែលបានសង់អង្គរវត្តហៅថា ព្រះពិស្ណុការ ដែលចេញមកពីមហាវិស្ណុការ ឬមហាពិស្ណុការ ។ រឿងព្រះពិស្ណុការ គឺជារឿងព្រេងដំណោលលើកដំកើងលំអសំរស់អង្គរវត្ត ។

**៦- អំពីព្រះរាជពង្សាវតារខ្មែរ៖** ដូចយើងបានរៀបរាប់ពីខាងដើម ព្រះរាជពង្សាវតារខ្មែរ ដែលចាស់ជាងគេដែលគេរកឃើញគឺ ព្រះរាជពង្សាវតារខ្មែរសរសេរនៅឆ្នាំ១៨១៨ ដោយបណ្ឌិតចក្រី*ឥង* គ្រូបាធ្យាយដ៏ចំណានម្នាក់របស់អង្គឌួង ។ ព្រះរាជពង្សាវតារទី២ ដែលពេញលេញជាងគេ ហើយដែលអ្នកប្រវត្តិសាស្ត្របារាំងតែងប្រើប្រាស់ បានសរសេរនៅឆ្នាំ ១៩២៩ តាមព្រះរាជពង្សាវតារទីមួយ ហើយសំរួលបំពេញសារឡើងវិញដើម្បីផ្សាយនៅឆ្នាំ ១៩៣៤ ។ គឺជាព្រះរាជពង្សាវតាររបស់សម្តេច*ចៅហ្វាវាំងជួន* ។ ប៉ុន្តែ ព្រះរាជពង្សាវតារទាំងនេះពុំដែលបោះផ្សាយជាសាធារណៈទេ ទោះជានៅសម័យរដ្ឋការអាណានិគមក្តី ឬ នៅសម័យរដ្ឋការខ្មែរឯករាជក្តី ។ ជាសំណាង

ល្អ ព្រះរាជពង្សាវតារនេះត្រូវបានបកប្រែជាភាសាបារាំង ដោយលោក ម៉ក់ភឿន និងលោក ម៉ិចសុក អ្នកសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរ ។

អំពីបញ្ហាថាខ្មែរមានប្រវត្តិខាងសំណេរ មានប្រពៃណីចារសរសេរ ពុំមែនមានត្រឹមតែប្រពៃណីនិយាយតាមមាត់ទេនោះ លោក*ម៉ិចសុក* បានបញ្ជាក់ក្នុងអត្ថបទមួយរបស់លោកថា៖ *ភាពការនិពន្ធរបស់លោកទៅឡាវ៉ាំងជួន ព្រះមហាក្សត្រព្រះនាមព្រះចន្ទរាជា ដែលមានឈ្មោះអភិសេកថា ព្រះបរមរាជាធិរាជរាមាធិបតី ពិតជាត្រូវនឹងឈ្មោះដែលស្ដេចទាំងឡាយ បានចារជាបន្តបន្ទាប់គ្នាលើសិលាចារឹកពីមុនមក ឥតមានកែប្រែ ។ ព្រះមហាក្សត្រនេះ ក្រោយពីកំចាត់ស្ដេចកនហើយ ក៏បានសោយរាជ្យពីឆ្នាំ១៥២៩ ដល់ឆ្នាំ១៥៦៧ គឺ៣៨ឆ្នាំ* ។ ការចារឈ្មោះស្ដេចដោយឥតមានខុស ពីជំនាន់មួយទៅជំនាន់មួយនេះ បានសេចក្ដីថា អ្នកនិពន្ធព្រះរាជពង្សាវតារខ្មែរ បានផ្អែកលើឯកសារសរសេរ ពុំមែនចេះតែប្រឌិតទេក្នុងការសរសេរប្រវត្តិរបស់ជាតិខ្លួន ។ យើងអាចសន្និដ្ឋានបានថា ខ្មែរមានប្រពៃណីសរសេរបន្តគ្នា ។

បច្ចុប្បន្ននេះ អ្នកស្រាវជ្រាវបរទេសទាំងឡាយ ទោះជាលោក*ស៊ែដេស* ក៏ដោយ ក៏បានយល់ស្របដែរថា ព្រះរាជពង្សាវតារខ្មែរ នៅតែជាប្រភពមួយដ៏ហ្មត់ចត់ ដែលគេអាចទុកចិត្តលើសេចក្ដីពិតនៃប្រវត្តិសាស្ត្រខ្មែរបាន ។ ខ្មែរយើងពិតជាមាន

ឯកសារ គម្ពីរច្រើនទៀតក្រៅពីព្រះរាជពង្សាវតារ ។ ប៉ុន្តែព្រះរាជពង្សាវតារចុងក្រោយ ឆ្នាំ ១៩៣៤ បានផ្អែកសង្កត់ឈរលើឯកសារណាខ្លះ? ហេតុអ្វីបានជាគេមិនបោះផ្សាយឯកសារដើមទាំងស្រុង?

រហូតដល់ថ្ងៃនេះ រដ្ឋការកម្ពុជាយើងទាំងឡាយ ពោលគឺពុំសូវបានគិតអំពីសារៈសំខាន់នៃប្រវត្តិសាស្ត្រទេ ដើម្បីលត់ដំសតិអារម្មណ៍ជាតិយើង កម្លាំងជាតិយើងឱ្យបានស្អិតរមួតគ្នាឡើង ។ កូនខ្មែរភាគច្រើនណាស់ ស្គាល់ប្រវត្តិសាស្ត្រខ្លួនត្រឹមតែតាមបំណែកៗ ទាំងស្រពិចស្រពិល លើប្រវត្តិសំខាន់ធំៗរបស់ដូនតាខ្លួន ។ បើកូនខ្មែរស្គាល់ប្រវត្តិដូនតាខ្លួនមិនច្បាស់ ស្គាល់ភូមិសាស្ត្រទឹកដីខ្លួនមិនច្បាស់ តើយើងអាចការពារទឹកការពារដីយើងបានយូរអង្វែងទេ? ប្រទេសឯករាជទាំងឡាយលើសកលលោកតែងមានវិជ្ជាស្ថានជាតិខាងប្រវត្តិសាស្ត្រនិងភូមិសាស្ត្រ ។ ចុះហេតុអ្វីក៏ខ្មែរយើងគ្មាន? ចុះហេតុអ្វីក៏ផែនទីភូមិសាស្ត្រខ្មែរត្រូវតែទៅបោះពុម្ពនៅស្រុកយួនទៅវិញ? តើការល្ងិតល្ងង់លើប្រវត្តិសាស្ត្រខ្លួននេះ ពុំមែនជាមូលហេតុមួយដែលនាំឱ្យយើងរងកម្មផលសព្វថ្ងៃនេះទេឬ?

ដើម្បីសរសេរប្រវត្តិសាស្ត្ររបស់ជាតិមួយ ចាំបាច់ត្រូវចងក្រងព្រឹត្តិការណ៍ ហើយជ្រើសរើសយ៉ាងហ្មត់ចត់នូវព្រឹត្តិការណ៍ទាំងឡាយណាដែលកំណត់បានថាជាព្រឹត្តិការណ៍ រាប់ជាប្រវត្តិសាស្ត្របាន ។ ព្រឹត្តិការណ៍មានហើយ តែនាទីទីពីរសំខាន់

របស់អ្នកប្រវត្តិសាស្ត្រគឺការបកប្រែព្រឹត្តិការណ៍ ។ ប្រវត្តិសាស្ត្រ ពុំមែនជាវិទ្យាសាស្ត្រទេ ព្រោះការបកស្រាយព្រឹត្តិការណ៍តែងតែវិវត្តន៍ទៅតាមចិត្ត និងទស្សនៈ បំណងរបស់អ្នកប្រវត្តិសាស្ត្រម្នាក់ៗ ទោះជាអ្នកនោះធ្វើដោយដឹងខ្លួនក្តី ឬ មិនដឹងខ្លួនក្តី ។ ជាក់ស្តែងបំផុត យួនសរសេរប្រវត្តិសាស្ត្រខ្មែរ តែងតែបំបែរឱ្យខ្មែរដឹងគុណយួនជានិច្ច ។ ប៉ុន្តែយួនគេសរសេរលេចធ្លោ ជ្រងោរកណ្តាលវាំងពេក ហាក់ដូចគេចាក់ប្រេងសាំងលើចិត្តខ្មែរ ។ ប៉ុន្តែ ការបកស្រាយព្រឹត្តិការណ៍ខ្មែរដោយអ្នកនិពន្ធបរទេសខ្លះ ក៏មិនអាចជៀសការលំអៀងផ្សេងៗដែរ ។ នេះជាការធម្មតា ។ នៅប្រទេសបារាំង ក្រោយចាញ់សង្គ្រាមឆ្នាំ ១៨៧០ អ្នកប្រវត្តិសាស្ត្របារាំងបានខំសរសេរយ៉ាងមមាញឹក ដោយខំផ្ចិតផ្ចង់ប្រវត្តិសាស្ត្រជាតិខ្លួនឡើងវិញ ដែលជាការរៀបចំឱ្យបានជ័យជំនះនៅឆ្នាំ ១៩១៨ ។ អ្នកប្រវត្តិសាស្ត្របារាំងជាច្រើនយល់ឃើញការចាំបាច់លើកដំកើងប្រវត្តិជាតិខ្លួន ជាពិសេសលោក *អឺរណែសឡាវីស* (Ernest Lavisse) បានសរសេរថា៖ A l'enseignement historique incomble le glorieux devoir de faire aimer et de comprendre la patrie... nos ancêtres gaulois et les forêts de druides, Charles Martel à Poiteirs, Roland à Roncevaux, Godefroy de Bouillon à Jérujalem, Jeanne d'Arc, tous nos héros du passé, même enveloppés de légende... Si l'écolier n'emporte

pas avec lui le vivant souvenir de nos gloires nationales, s'il ne sait pas que nos ancêtres ont combattu sur mille champs de bataille pour de nobles causes, s'il n'a point appris ce qu'il a coûté de sang et d'efforts pour faire l'unité de notre patrie et de dégager ensuite le chaos de nos institutions vieilles des lois sacrées qui nous ont fait libres, s'il ne devient pas un citoyen pénétré de ses devoirs et un soldat qui aime son drapeau, l'instituteur aura perdu son temps. បានសេចក្តីជាសង្ខេបថា នាទីដ៏ខ្ពង់ខ្ពស់របស់គ្រូបង្រៀន គឺធ្វើឱ្យសិស្សស្គាល់នូវថ្លៃវីរៈភាពរបស់បុព្វបុរសជាតិទាំងឡាយ ដែលបានបង្ហូរឈាមដើម្បីជាតិ នៅលើសមរភូមិផ្សេងៗ ធ្វើឱ្យសិស្សមានអនុស្សាវរីយ៍ អំពីការខំប្រឹងប្រែងដោយញើសដោយឈាមទាំងឡាយដើម្បីឯកភាពជាតិ និងដើម្បីរំដោះជាតិឱ្យចេញផុតពីអវចីយនៃច្បាប់ទំលាប់ចាស់ និងឱ្យឃើញថា ដោយសារការបូជាទាំងឡាយរបស់វីរៈបុរសនេះហើយ ដែលនាំឱ្យយើងមានសេរីភាព ។ បើយើងមិនអប់រំឱ្យសិស្សយើង ក្លាយទៅជាពលរដ្ឋ ជ្រួតជ្រាបទៅដោយភារៈកិច្ចស្រឡាញ់ទង់ជាតិរបស់ខ្លួនទេ ពេលនោះ គ្រូបង្រៀននឹងពិតជាខាតពេលវេលារបស់ខ្លួនជាប្រាកដ(៣៨) ។ លោកអេដវើដខារ (Edward H.Carr) អ្នកប្រវត្តិសាស្ត្រអង់គ្លេសម្នាក់សរសេរថា៖ ដើម្បីឱ្យកូនចៅយើងមានមោទនៈភាពចំពោះជាតិខ្លួន អ្នកប្រវត្តិសាស្ត្រយើង

មានភារៈកិច្ចបង្ហាញកំពូលភ្នំដ៏ស្ដឹមស្ដៃដល់ប្រជានិករយើង ឱ្យបានជាអតិបរមា ហើយបង្ហាញជ្រោះជ្រលងអវិចីយឱ្យបានតិចជាអប្បបរមា(៣៧) ។

ជាតិខ្មែរត្រូវការណាស់អ្នកប្រវត្តិសាស្ត្រខ្មែរ ។ យើងចាំបាច់ប្រើឯកសារបរទេសដែលគេបានសរសេរទុកមក ប៉ុន្តែជាតិខ្មែរចាំបាច់មានអ្នកប្រវត្តិសាស្ត្ររបស់ខ្លួន ចំនួនច្រើនទៀត ។ តើខ្មែរយើងមានអ្នកប្រវត្តិសាស្ត្ររបស់ខ្លួនចំនួនប៉ុន្មាន ដែលគេអាចចងចាំបាន? បើពិនិត្យទៅ ទាំងរស់ទាំងស្លាប់ យើងនៅមានចំនួនតិចបំផុត ជាពិសេសចំនួនអ្នកសរសេរប្រវត្តិសាស្ត្រតាមបែបសាមញ្ញទំនើបជាភាសាខ្មែរ រឹតតែមានចំនួនតិចណាស់ទៅទៀត ។ យើងមិនភ្លេចទេ ឈ្មោះអ្នកសរសេរប្រវត្តិសាស្ត្ររបស់យើងដែលយើងធ្លាប់ឮ ដូចជាលោកនិងលោកស្រី *ត្រឹងងា* លោកស្រីបណ្ឌិត *សៅសារេស* លោក *ទួនយៀន* លោក *ហ៊ីទីម* លោក *ប៊ុនចន្ទម៉ុល* លោក *ត៉ុកសាវ៉ុ* លោកបណ្ឌិត *ម៉ិនសុក* លោកបណ្ឌិត *ម៉ក់ភឿន* លោកបណ្ឌិត *ម៉ីសាន់ណារ៉ា* លោកបណ្ឌិត *វ៉ាន់ម៉ីកាសុន* លោកបណ្ឌិត *សារិនឆាក* (លោកសារិនឆាក ត្រូវឃុំខ្លួនទាប់ខ្លួននៅខែមករា១៩៧៥ នៅភ្នំពេញ ហើយបាត់ដំណឹងសូន្យឈឹង) ។ យើងរាប់ឈ្មោះនៅពេលនេះ ពិតជាមានការភ្លេចចន្លោះមិនខាន ។ ប៉ុន្តែអ្នកប្រវត្តិសាស្ត្រខ្មែរយើងដឹងកម្នាក់ដែលត្រូវដាក់ជូន នូវគ្រប់កិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត à tout seigneur tout honneur គឺលោកសាស្ត្រា

ចារ្យ *អូឌោង* ដែលជាគ្រូបង្រៀនបាលីសំស្ក្រឹត នៅសាលាវិជ្ជាជាន់ខ្ពស់ប្រទេសបារាំង ។ លោក*អូឌោង* ជាអ្នកឯកទេសខ្មែរដ៏ចាស់ជាងគេ ដែលស្គាល់ភាសាខ្មែរបូរាណលើសិលាចារឹក ។ លោក*សឺដេស* តែងធ្លាប់និយាយថា ឯកសាររបស់លោក *អូឌោង* អាចធ្វើជាវចនានុក្រមភាសាខ្មែរបូរាណបាន ។ ប៉ុន្តែថវិការនៅតែជាឧបសគ្គក្នុងការបោះពុម្ពផ្សាយ ។ រហូតដល់ថ្ងៃនេះ កូនខ្មែរមិនសូវស្គាល់ឈ្មោះលោក *អូឌោង* ទេ ។ រដ្ឋាភិបាលខ្មែរទាំងឡាយ ពុំដែលបានយកចិត្តទុកដាក់ដល់ថ្លៃរបស់លោក*អូឌោង* ឱ្យបានដល់កំរិតឡើយ ។ អ្នកនយោបាយខ្មែរ កន្លងមក ហាក់នៅតែបែរខ្នងដាក់អ្នកប្រវត្តិសាស្ត្រជាតិខ្លួន ។ អ្នកស្រាវជ្រាវបារាំងតែងតែពឹងពាក់លើលោក *អូឌោង* ជាពិសេសលោក *សឺដេស* តែងតែត្រូវការលោក*អូឌោង* ក្នុងគ្រប់ការបកប្រែភាសាខ្មែរបូរាណលើសិលាចារឹក ។ អ្នកប្រវត្តិសាស្ត្រ ជាទ្រព្យសម្បត្តិរបស់ជាតិ ។ អ្នកប្រវត្តិសាស្ត្រខ្មែរដែលសរសេរជាភាសាខ្មែរ នៅមានចំនួនតិចតួចស្ទើង ជាការគួរឱ្យសោកស្តាយ ។

ប្រវត្តិសាស្ត្ររបស់ជាតិនិមួយៗ តែងតែសរសេរដោយអ្នកប្រវត្តិសាស្ត្ររបស់ខ្លួន ទោះជាជាតិណាក៏ដោយនៅលើលោកនេះ ។

***ប្រវត្តិសាស្ត្រ គឺជាការសារសងសន្តានរវាងបច្ចុប្បន្នកាល និងអតីតកាល ដើម្បីស្វែងរកអនាគត ។ ជំនាន់បច្ចុប្បន្ន នៅ***

តែជាបណ្ដាលត្រូវបង់ចិត្តសំរាប់ជំនាន់អនាគត ។ បើគ្មានប្រវត្តិសាស្ត្រសរសេរដោយជំនាន់បច្ចុប្បន្ននេះទេ ខ្សែតំណរបន្តជីវិតជាតិ ត្រូវកាត់ផ្ដាច់ពីអតីតកាលទាំងស្រុង ។ កូនចៅយើងនឹងគិតថាខ្លួនសាងសង់ឡើងឡើយជាមួយបុព្វបុរសខ្លួន ជាមួយដូនតារបស់ខ្លួនគ្មានទៀតហើយ ។ បើគ្មានការសាងសង់ គ្មានការសន្តានជាមួយអតីតកាលហើយ យើងហាក់ទុកឲ្យកូនចៅយើងក្លាយទៅជាកូនកំព្រាឯងគ្មានអតីតកាល ។ មនុស្សគ្មានអតីតកាល ដូចមនុស្សភ្លេចអតីតកាលខ្លួន ជាមនុស្សបាត់វិញ្ញាណ។ ជាតិគ្មានប្រវត្តិសាស្ត្រក៏ដូច្នេះដែរ ។ ហេតុនេះ ស្នាដៃរបស់អ្នកប្រវត្តិសាស្ត្រខ្មែរដែលស្នេហាជាតិមាតុភូមិនីមួយៗ ទុកដូចជាឈាមថ្មី ដែលចាក់បញ្ចូលទៅក្នុងសរសៃប្រវត្តិសាស្ត្ររបស់ជាតិខ្លួនដូច្នេះដែរ ។



# ឯកសារសន្ទស់


1. ***Mak Phoeun***, "La frontière entre le Cambodge et le Viêtnam du XVIIè siècle à l'instauration du protectorat français présentée à travers les chroniques royales khmères" in "Les frontières du Viêtnam" , P.B. Lafont, l'Harmattan Paris 1989 , p. 136-155;
2. ***P.Gourou*** 1940 p. 139 . cité par Mak Phoeun:
3. ***Ch. Robequain***, in S. Levi 1931, 1, p. 31 , cité par Mak Phoeun;
4. ***Bernard Philippe GROSLIER***, cahiers d'Outre-Mer, 1973, p.362, cité par Mak Phoeun;
5. ***Pierre-Lucien Lamant***, "La frontière entre le Cambodge et le Viêtnam du milieu du XIXè siècle à nos jours" in " Les Frontières du Vietnam", P. B. Lafont, L'Harmattan 1989 p. 156;
6. ***Michel Foucher***, Fronts et Frontières, Fayard 1992;
7. ***Jean Delvert***, "Le Paysan Cambodgien", Mouton & Co, 1961;
8. ***Hu Nim***, Situation juridique du Kampuchea Krom , Mémoire pour le Diplome d'études supérieures de droit public de la Faculté de droit et des sciences économiques de Phnom Penh;
9. ***M. A. Pétiton***, 1895 , p. 31 et 32;
10. ***A. B. de Villemereuil***, 1883, p. 77 et 78;

11.*Mak Phoeun*, op. cit. p. 148-149;

12.*Alain Forest*, Le Cambodge et la Colonisation française, l'Harmattan, 1980;

13.*Sarin Chhak*, "Les frontières du Cambodge", Ed. Dalloz, 1966;

14.Journal officiel (français), du 21-25 mai 1949;

15.*ត្រឹង ងា* ប្រវត្តិសាស្ត្រខ្មែរ អប្សរា(បោះពុម្ព)១៩៩៩;

16.*Khing Hoc Dy*, Ecrivains et expressions littéraires du Cambodge au XXème siècle-L'Harmattan, 1993;

17.*Jacques Reclus*, "La Révolte des Taïping (1851- 1864) prologue de la Révolution chinoise", Le Pavillon Roger Maria Editeur;

18.*Claude Lévi-Strauss*, "Conservation, contrainte et culture" in "Culture pour tous et pour tous les temps", ed. UNESCO, 1984;

19.*Dufosse*, "Monographie de la circonscription résidentielle de Kompong Thom, cité par Alain Forest, "Histoire de l'Asie du Sud-Est, Révolte, Réformes, Révolutions", Ed. Presse Universitaire de Lille, 1981;

20.*René Charbonneau*, "De la décolonisation chinoise à la colonisation vietnamienne", in "Indochine. Alerte à l'histoire", Institut de l'Asie du Sud-Est, 1985, p.87;

21.*Charles Henri Bonfils*, "De la décolonisation vis-à-vis de la Chine..." in "Indochine. Alerte à l'Histoire." p. 89;

22.*Khy Phanra*, "La communauté vietnamienne au Cambodge à l'époque du Protectorat français", Thèse de doctorat, Université de la Sorbonne nouvelle, Paris III, 1974;

23.*Adhémard Leclère*, "Histoire du Cambodge", Ed. Nokor Thom Editeur, Phnom-Penh, 1974, 1ère édition: Librairie Paul Geuthner, Paris 1914;

24.*Hu Nim*, "Situation juridique du Kampuchea Krom", Mémoire pour D.E.S. de Droit Public, Phnom-Penh;

25."Hommes et Destins", Académie des sciences d'Outre-Mer, tome VI Asie, 1985, biographie d'Auguste Pavie, p.323;